រ.តោរិទ

# ព្រះរាជពង្សាវតារ
# នៃ
# ប្រទេសកម្ពុជា



CA 34

## រ.គោទិន

អតីតសាស្ត្រាចារ្យនៅវិទ្យាល័យស៊ីសុវត្ថិ

# ព្រះរាជពង្សាវតារ

# នៃ

# ប្រទេសកម្ពុជា

## សម្រាប់ថ្នាក់

បឋមភូមិបំពេញវិជ្ជាទូទៅ

បោះពុម្ពលើកទី ១

ការផ្សាយរបស់

បណ្ណាគារអាវុធ

ផ្ទះលេខ ៣៣២ វិថីកម្ពុជាក្រោម

និងតូបលេខ ៩៣ រុក្ខវិថីខុកញ៉ាផ្លុង (ភ្នំពេញ)

ព.ស. ២៥០៩ គ.ស. ១៩៦៧

-រក្សាសិទ្ធិគ្រប់យ៉ាង-

# សេចក្ដីផ្ដើម

យើងបានសន្សំឯកសារផ្សេង ៗ ខាងពង្សាវតារ អស់ពេលជាច្រើនឆ្នាំមកហើយ ។ យើងបានរៀបរៀង ពង្សាវតារប្រទេសកម្ពុជា តម្រូវតាមកម្មវិធីសិក្សាបួនបែប ផ្សេងគ្នា ។ ប៉ុន្តែឯកសារថ្មី ៗ ទៀត បានតម្រូវអោយ យើងរៀបរៀងជាថ្មីទៀតដែរ ។ រីឯសារៈសំខាន់នឹងហុច ប្រយោជន៍យ៉ាងណាៗ ដល់អ្នកសិក្សានោះស្រេចតែវិនិច្ឆ័យ ទៅចុះ ។ ប៉ុន្តែតាមធម្មតា , កិច្ចការចុងក្រោយ ឬកិច្ច ការថ្មី មុខជានឹងបញ្ជាក់នូវការចំរើនលូតលាស់ថ្មីដែរ ។

ទុកជាយ៉ាងណាក៏ដោយ យើងសង្ឃឹមថា អ្នកសិក្សា មុខជាអាចក្រេបយកប្រយោជន៍អំពីសៀវភៅនេះ យ៉ាង ច្រើនជាពុំខាន ។

ភ្នំពេញ , ថ្ងៃ ២៩ ធ្នូ ១៩៦៧

**រ.គោវិទ**

# សករាជ

សកៈ បានសេចក្ដីថា ((កាល, សម័យ, យុគ)) តភ្ជាប់និងរាជ ((ស្ដេច))រួចហៅថា ((សករាជ)) ។ សករាជនេះគេលើកយកអច្ឆរិយបុគ្គល ឬស្ដេចអង្គណាមួយមកជាល័ក្ខកេណ្ឌ ។ បានសេចក្ដីថា ការកំណត់រាប់ឆ្នាំជាតំណពីស្ដេចឬអច្ឆរិយបុរសដ៏ទ្រទ្រង់អំណាចដែលសុគតទៅ ។

សករាជមាន ៤យ៉ាងគឺ

១- ពុទ្ធសករាជ ។

២- គ្រិស្ដសករាជ ។

៣- មហាសករាជ ។

៤- ចុល្លសករាជ ។

១-ពុទ្ធសករាជ- កំណត់កាលពីថ្ងៃ-ខែ ឆ្នាំ ដែលព្រះពុទ្ធនិព្វានហើយ គឺថ្ងៃពុធ ១រោជ ខែពិសាខ ឆ្នាំម្សាញ់ ក្រោយពីថ្ងៃដែលព្រះបរមគ្រូទ្រង់និព្វាន កាលថ្ងៃអង្គារ ១៥ កើត ខែពិសាខរៀងរាបផរាបមក , គេសរសេរកាត់ថា ព . ស . ។

២-**គ្រិស្តសករាជ** កើតឡើងខាងក្រោយព្រះពុទ្ធសាសនា ៥៤៣ ឆ្នាំ ដោយមានអ្នកប្រាជ្ញម្នាក់ឈ្មោះ យេស៊ូ ឬយេស៊ូគ្រិស្ត ជាអ្នកផ្តើមបង្កើតសាសនា គ្រេជាង ឬ សាសនាគ្រិស្ត ។ កើតនៅប្រទេស ((ប៉ាឡេស្ទីន)) ក្នុងសតវត្សទី ៦ នៃព្រះពុទ្ធ សករាជ ( ព . ស. ៥៤៣ ) ។ លោកនេះទទួលមរណភាព ក្នុងអាយុគ្រប់ ៣៣ ឆ្នាំ ក្នុង ព.ស. ៥៧៦ គេសរសេរកាត់ថា គ.ស. ។

៣-**មហាសករាជ** កើតមានឡើងក្នុងរាជ្យ ព្រះបាទសកៈ ឬ សាលីវាហនៈ នៅក្នុងប្រទេសឥណ្ឌា ក្នុងរវាង ព.ស. ៦២១, ដោយប្រារព្ធយកហេតុនៃជ័យជំនះយ៉ាងសម្បើមអស្ចារ្យ របស់ក្សត្រអង្គនេះជាកេណ្ឌ ។ ក្រោយមកទើបគេថែមសករាជ ព្រះបាទសាលីវាហនៈថា (( **មហាសករាជ** )) គេសរសេរកាត់ថា ម. ស. ។

ក្នុងព្រះរាជពង្សាវតារខ្មែរថា ព្រះបាទសម្តេចព្រះអរិន្ទពលពាហនោ ព្រះកេតុមាលាសូរ្យវង្ស បានតាំងមហាសករាជ ១ ក្នុង ព. ស. ៦២១ ឆ្នាំ ។

តាមសេចក្តីខាងក្រោមនេះ មហាសករាជគឺប្រារព្ធនូវជ័យជំនះរបស់ស្តេចខ្មែរ ។

ត្រង់នោះគួរយល់ថាត្រូវជាង ព្រោះជ័យជំនះ ស្តេចឥណ្ឌាមុខជាខ្មែរយើងពុំមែនយកមកប្រើក្នុងប្រទេសខ្លួនទេ ។

ក្នុងពង្សាវតារនគរជៀងហ្មៃ (លាវ) ដំណាលថា ព្រះបាទពន្ធុមតីគង់ក្នុងប្រទេសលង្កា ទ្រង់តាំងមហាសករាជឡើង ។

តែបើតាមពិតនោះ គឺព្រះបាទសាលីវាហនៈ ទ្រង់តាំងឡើង

ហើយព្រះបាទ ពន្ទុមតី គ្រាន់តែយកទៅប្រកាសអនុវត្តប្រើក្នុងប្រទេសរបស់ព្រះអង្គប៉ុណ្ណោះ ។

៤-ចុល្លសករាជ មានក្សត្រភូមា ១២ អង្គទ្រង់ព្រះនាម ((សង្ស៊ីរាជ)) ឬហៅថា បុប្ផសោហោន៍ ជាក្សត្រទី ១៩ក្នុងវង្សសមុទ្ទបុទ្ធិ ទ្រង់ផ្តើមតាំងឡើងក្នុងឆ្នាំកុរ ដែលគេរាប់ជាឆ្នាំឯកស័កគឺក្នុង ព.ស. ១១៨២ ដោយយកសុរិយាគតិ គឺពេលប្រជួបខួបនៃព្រះអាទិត្យគោចរ ចេញអំពីមេសរាសី ហើយត្រឡប់មកដល់មេសរាសីវិញជាកេណ្ឌ , គឺកំណត់ក្នុងថ្ងៃទី ១៣- ១៤ខែមេសា ត្រូវគ្នានឹងខែពិសាខតាមចន្ទគតិ, ហើយកំណត់ពាក្យឯកស័ក , ទោស័ក , ត្រីស័ក , ជាដើមរៀងតមក , គេសរសេរអក្សរកាត់ថា ច.ស. ។

គេចាំបានថា ព្រះបាទសម្តេចព្រះសិន្ធពរមរិន្ទព្រហ្មកិឍ (ពញាក្រែក) បានតាំងសករាជ១ដែរ,ប៉ុន្តែក្នុង ព.ស.១១៨១ ។

បើតាមកំណត់សករាជ នៃព្រះបាទអមរិន្ទព្រហ្មកិឍឃើញថាតាំងមុនក្សត្រភូមា ១២ អង្គចំនួន ១ឆ្នាំ ។ ដូច្នេះចុល្លសករាជស្តេចភូមាបានកំណត់លើសមួយឆ្នាំទៅវិញ យើងពុំត្រូវយក សក-រាជស្តេចជាតិណាមកស៊ើបសន្តវង្សក្នុងប្រទេសយើងឡើយ ។

# សិលាចារឹក

ក្នុងអតីតកាល ព្រះមហាក្សត្រខ្មែរមានឫទ្ធានុភាពព្រមទាំងធនធានយ៉ាងបរិបូណ៌ សឹងមានប្រាសាទថ្មដ៏ល្អវិចិត្រជាភស្តុតាងអោយយើងឃើញរហូតដល់សព្វថ្ងៃនេះស្រាប់ ។ គេឃើញអក្សរខ្មែរបុរាណជាភាសាបាលី និង ជាភាសាសំស្ក្រឹត ចារឹកនៅតាមកំពែងប្រាសាទទាំងនោះ ដើម្បីបញ្ជាក់នូវឫទ្ធិចេស្តានៃព្រះមហាក្សត្រនិមួយៗ តាមរាជ្យរបស់ព្រះអង្គ ។ ប៉ុន្តែអក្សរសិលាចារឹកនោះ គ្មានអ្នកណាចេះប្រាកដទេ មានតែអ្នកប្រាជ្ញជាតិបារាំងសែសម្នាក់ឈ្មោះ អៃម៉ូនីញេរ៍ (Aymonier) ទើបចេះអក្សរនោះជាក់លាក់ ។

ដោយសារសិលាចារឹកទាំងនោះហើយ ទើបបានជាគេអាចដឹងថា ប្រទេសកម្ពុជា ជារដ្ឋមួយមានចេស្តាបារមី ព្រមទាំងធនធានច្រើនលើសប្រទេសនានា នៅបែកចុងបូព៌ាប្រទេស ។ កេរ្តិ៍ឈ្មោះរបស់ប្រទេសកម្ពុជាក៏ល្បីល្បាញខ្ចរខ្ចាយ ទៅគ្រប់ពិភពមណ្ឌលនាំអោយជនបរទេសខ្វល់ខ្វាយនឹកស្ទះស្វែងចង់មកទស្សនា ប៉ុន្តែគេដឹងថា ជនជាតិចិនមកមើលមុនជាតិដទៃ ។ ដល់មក គ. ស. ១.៨០០ ទើបមានជនជាតិអឺរុបមកទស្សនា គឺពរទុយគេស៍ , អេស្ប៉ាញ្ញោល និង ហុល្លង់ដេស៍ជាដើម ហើយបានកត់ត្រាទុកនូវពត៌មានផ្សេងៗ ទុកឲ្យយើងដឹងត ៗ មក ។

# កំណើតនៃប្រទេសកម្ពុជា

កាលពីសម័យព្រេងនាយ ប្រទេសកម្ពុជា និង ដែនកូសាំងស៊ីន (ប្រទេសយួនខាងត្បូង) សព្វថ្ងៃនេះ ជាសមុទ្រទាំងអស់ លាតសន្ធឹងទៅខាងកើតទល់នឹងជួរភ្នំអណ្ណាម ខាងជើងទល់នឹងភ្នំដងរែក ហើយខាងលិចទល់នឹងជួរភ្នំកំចាយ ។ គេឃើញកោះជាច្រើន នៅក្នុងផ្ទៃសមុទ្រនោះ ។ ទន្លេមេគង្គបាននាំដីល្បាប់មកចាក់បំពេញបន្តិចម្តង ៗ រហូតដល់បានកើតទៅជាកោះមួយយ៉ាងធំឈ្មោះថា (( កោះគោកធ្លក )) ។ ទីកោះនោះតាំងនៅត្រង់អង្គរបុរី ស្រុកព្រៃកប្បាសខែត្រតាកែវសព្វថ្ងៃនេះ។

លុះដីមានទំហំរីតតែធំឡើង , ពួកមនុស្សក៏នាំគ្នាមកតាំងទីលំនៅ , នៅផ្សេងៗគ្នា ដោយពួកដោយក្រុមរៀង ៗ ខ្លួន មិនចំណុះចុះចូលនឹងគ្នាឡើយ ។ មនុស្សទាំងនោះស្រាតនៅខ្លួនទទេ សាក់ពេញខ្លួន ហើយមិនចេះត្បាញសំពត់ស្លៀកពាក់ឡើយ ។ ខ្លះសង់ខ្ទមនៅលើគោក ខ្លះនៅដោយទូកក្នុងទឹក។ អ្នកនៅប៉ែកដីខ្ពស់ រកស៊ីបរបាញ់សត្វ , អ្នកនៅប៉ែកដីទំនាបរករបរនេសាទត្រី , កាលនោះពួកចិនទេសចរ បានមកឃើញហើយហៅ កោះគោកធ្លកនេះថា (( ហ្វូណាន )) (១) ។ ប្រជាជនហ្វូណាននេះ លើកស្ត្រីមួយនាក់ ហៅតាមភាសាចិនថា (( ព្រះនាងលីវយី )) អោយធ្វើជារាជិនីសម្រាប់គ្រប់គ្រងប្រទេស ។

---

១- ហ្វូណាន ជាភាសាចិនហៅតាមខ្មែរ ( ភ្នំ ) ។

# ១- ព្រះបាទហ៊ុនទៀន

(ពីគ.ស. ៦៨ ដល់ ... រាជធានីគោកធ្លក)

នៅក្នុងចន្លោះ គ.ស. ៦៨ មានជាតិព្រាហ្មណ៍ម្នាក់ នាមហ៊ុនទៀន,មកពីប្រទេសឥណ្ឌៀប៉ែកអគ្នេយ៍បានលើកទ័ពតាមផ្លូវសមុទ្ទ ចូលមកច្បាំងយកនគរហ្វូណន ។លុះច្បាំងឈ្នះហើយក៏ឡើងសោយរាជសម្បត្តិ ព្រមទាំងលើកព្រះនាងលើវយើជាមហេសី ហើយផ្លាស់ព្រះនាមរបស់ព្រះនាងជា នាងសោមា (កូនព្រះច័ន្ទ) វិញ ។ ក្នុងរជ្ជកាលព្រះរាជាអង្គនេះ ប្រជាជនខ្មែរ ចេះត្បាញ-សំពត់ស្លៀកពាក់ហើយ ។ ប្រទេសខ្មែរកាលនោះបានផ្លាស់ឈ្មោះជាញ៉ឹកញូយ ដំបូងផ្លាស់ពីគោកធ្លកមកជា (តក្កសី លា) ក្រោយមកផ្លាស់ជា (ឥន្ទបត្តយសោធរៈ) ក្រោយមកទៀតផ្លាស់ជា (មហានគរកម្ពុជាធិបតីសិរីឥន្ទ-បត្តកុរុរដ្ឋរាជធានី) ។ ព្រះបាទហ៊ុនទៀន និងព្រះនាង-សោមា មានរាជបុត្រាមួយព្រះអង្គសោយរាជ្យស្នង និងបន្តក្រសែព្រះរាជវង្សានុវង្ស តមកបានជាង ២០០ ឆ្នាំ គឺចាប់តាំងពី គ.ស. ៦៨ ដល់ គ.ស. ២៨៥ ។

## ២- ព្រះបាទហ្វាន់ម៉ាន់

( . . . ដល់ ២៣០ = រាជធានី គោកធ្លក )

ក្សត្រអង្គនេះជាព្រះរាជវង្ស នៃព្រះបាទហ៊ុនទៀន ។ ទ្រង់មានសេចក្តីក្លាហាន , មានប្រាជ្ញាឈ្លាសវៃ និងមានឫទ្ធិតេជះពូកែណាស់ ។ ព្រះអង្គបានវាយយកប្រទេសជិតខាងធ្វើជាចំណុះគឺ ប្រទេសសៀម (ខាងត្បូង) និងប្រទេសថ្លាម៉ាឡាយូ ((សព្វថ្ងៃហៅថាម៉ាឡាកា)) ។ ជនជាតិក្នុងប្រទេសសម័យនោះត្រូវបែកជា ៤ត្រកូលគឺ ÷

១- ក្សត្រជាត្រកូលអ្នកចម្បាំងនិងអ្នកសាងនគរ ។

២- ព្រាហ្មណ៍ ត្រកូលអ្នកធ្វើគ្រូបង្រៀន ស្តេចនិង-ប្រជាជន។

៣- វេស្សៈ ត្រកូលអ្នកជំនួញ ឬ អ្នកធ្វើស្រែ ។

៤- សូទ្រៈ ត្រកូលអ្នកស៊ីឈ្នួលគេ ។

ជនទាំងបួនត្រកូលនេះ ប្រកាន់ឋានៈណាស់ មិនចូលរួមភាជនៈ ឬ យកគ្នាជាប្តីប្រពន្ធឡើយ ។

ព្រះបាទហ្វាន់ម៉ាន់ សោយរាជ្យមកដល់ គ.ស.២៣០ ក៏ត្រូវ ព្រះបាទហ្វាន់ចាន់ ជាព្រះភគិនិយោ (ក្មួយ) ធ្វើគតដណ្តើមរាជ្យទៅ ។ លុះដល់មក គ.ស. ២៤០ ព្រះបាទហ្វាន់ស៊ីយុន ក៏ធ្វើគតព្រះបាទហ្វាន់ចាន់បានវិញ ហើយឡើងសោរាជ្យតមក ។

# ៣- ព្រះបាទហាន់ស៊ីយុន

( ២៨០ ដល់ . . . = រាជធានី គោកធ្លក )

ព្រះមហាក្សត្រអង្គនេះ ជាព្រះរាជបុត្រព្រះបាទហ្វាន់-ម៉ាន់ ។ ក្នុង គ.ស. ២៨០ ដែលព្រះអង្គបានធ្វើគតព្រះបាទហ្វាន់ចាន់ហើយព្រះអង្គក៏ឡើងគ្រងរាជសម្បត្តិតមក។ ទ្រង់ជា ព្រះមហាក្សត្រប្រកបដោយឫទ្ធានុភាពខ្លាំងពូកែណាស់ ។ ដោយព្រះអង្គយល់ឃើញថា ការចងស្ពានមេ-ត្រី នឹង ប្រទេសជិតខាងជាកម្លាំងការពារសន្តិភាពក្នុងប្រទេស, ព្រះភូមិន្ទក៏ចងស្ពានមេត្រីនឹងប្រទេសចិនដោយមានបញ្ជូនសួយសារអាករទៅវិញទៅមក ។

គេអាចសំគាល់បានថា ព្រះបាទហ្វាន់ស៊ីយុនអង្គនេះជាព្រះមហាក្សត្រ ដែលមានឫទ្ធិខ្លាំងពូកែលើសលែងព្រះមហាក្សត្រ នានា ក្នុងព្រះរាជវង្សនៃព្រះបាទហ៊ុនទៀន។

# ៨- ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន

( ៤៨៥ - ៥១៤ = រាជធានី វ្យាធបុរៈ )

ក្នុងរវាងពាក់កណ្តាលសតវត្សរ៍ ទី៥ នៃគ្រិស្តសករាជ មានជាតិព្រាហ្មណ៍ត្រកូលកោណ្ឌញ្ញ ចេញពីផ្នែកខាងត្បូង នៃប្រទេសឥណ្ឌៀចូលមកលុកលុយ នគរគោកធ្លកម្តង-ទៀត ។ មេកងទ័ពនៃជាតិនេះ បានឡើយសោយរាជ្យ ហើយតាំងព្រះនាមថា (( ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន )) ព្រះរាជាអង្គនេះទ្រង់តាំង រាជធានីមួយនៅ អង្គរបុរី ខេត្រតាកែវសព្វថ្ងៃ ដោយឲ្យឈ្មោះថា ((វ្យាធបុរៈ )) មួយទៀតនៅសម្បូណ៌ ក្នុងខេត្រក្រចេះអោយឈ្មោះថា ក្រុង (( សម្ភុបុរៈ )) ។

ព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន បានរិតចំណងមេត្រីភាព រវាងប្រទេសចិនឲ្យកាន់តែមាំមួនណាស់ទៅទៀត ដើម្បីនឹងធ្វើសង្គ្រាមជាមួយប្រទេសចាម និងប្រទេសជិតខាង នៅទិសខាងកើតយកមកធ្វើជាប្រទេសចំណុះ ។ ព្រះអង្គ បានណែនាំប្រជាជនខ្មែរអោយស្រឡាញ់រាប់អានគោរព-សាសនាព្រាហ្មណ៍ និង ឥស្សូរ ។

ព្រះអង្គទ្រង់ចូលសុវណ្ណគតនៅ គ.ស. ៥១៤ ។

# ៥- ព្រះបាទភវវរ្ម័ន

( ៥៥០ ? ដល់ . . . = វ្យធបុរៈ )

ក្រោយពេលដែលព្រះបាទកោណ្ឌញ្ញជ័យវរ្ម័ន ទ្រង់សោយព្រះទិវង្គត់ទៅ ប្រទេសចំណុះទាំងឡាយមានប្រទេសចម្ប៉ាជាដើមបាននាំគ្នាបះបោរឡើងដណ្ដើមយកឯករាជ្យរៀង ៗ ខ្លួន ។ ប៉ុន្តែគ្រានោះមានក្សត្រមួយព្រះអង្គជាជាតិកម្ពុជះ បានវាយបង្ក្រាបពួកប្រទេសរណបទាំងនោះអោយរាបទាបបានវិញ ហើយព្រះអង្គក៏បានឡើងគ្រងរាជសម្បត្តិឡើង ក្នុង រវាង គ.ស. ៥៥០ ដោយមានព្រះនាមប្រាកដថា ((ព្រះបាទភវវរ្ម័ន)) ។ ព្រះរាជាអង្គនេះ ទ្រង់បានផ្លាស់ឈ្មោះប្រទេសហ្វូណនជា (កម្ពុជា) វិញដែលយើងប្រើជាប់រហូតដល់មកសព្វថ្ងៃ ។

ព្រះរាជអាណាចក្រកម្ពុជាក្នុងរាជ្យរបស់ ព្រះបាទភវវរ្ម័ន មានព្រំដែនលាតសន្ធឹងយ៉ាងធំធេង ស្ទើតែពេញឥណ្ឌូចិនទាំងមូលព្រោះ ព្រះអង្គជាក្សត្រសឹកដ៏ក្លាហានវាងវៃជាទីបំផុត ។

# ៦- ព្រះបាទព្ញាសានទវ័ន

( ៦១០ ដល់ ... - ញ្ញាសានបុរៈ )

ព្រះមហាក្សត្រខ្មែរទាំងឡាយ ដែលគ្រងរាជសម្បត្តិពីព្រះបាទភវវរ្ម័នមកនោះក៏សុទ្ធសឹងតែមានឫទ្ធិចេស្តាខ្លាំងពូកែទាំងអស់ ។ ក្នុង គ.ស. ៦១០ មានព្រះមហាក្សត្រមួយព្រះអង្គទ្រង់ព្រះមានថា (( ព្រះបាទញ្ញាសានវរ្ម័ន )) បានឡើងសោយរាជសម្បត្តិគ្រប់គ្រង ព្រះរាជណាចក្រទាំងមូល ។

ព្រះមហាក្សត្រអង្គនេះ បានសាងប្រាសាទជាព្រះរាជនីវេសនដ្ឋាន (១) និង បូជនីយដ្ឋាន (២) ប្រហែលជាង ២០.០០០

ប្រាសាទ ។ ព្រះអង្គសព្វព្រះរាជហឫទ័យទ្រង់នូវព្រះពស្ត្រព្រះភូសាពណ៌ក្រហម រំលេចទៅដោយផ្កាភ្ញីដ៏ល្អអស្ចារ្យ ។ នៅព្រះកាណ៌ទ្រង់ព្រះរយាំមាស នៅព្រះកេសទ្រង់ព្រះមកុដដាំត្បូងមានតំលៃផ្សេង ៗ ។ នៅគ្រប់តែទីកន្លែងដែលព្រះអង្គគង់នៅទ្រង់តែងត្រាស់បង្គាប់ឲ្យដុតឈើក្រអូបក្នុងផើងមាសថ្វាយជានិច្ច ។

---

១- ព្រះរាជនិវេសនដ្ឋាន = កន្លែងសម្រាប់ស្តេចគង់នៅ

២- បូជនីដ្ឋាន = កន្លែងសំរាប់បូជា, ទីដាក់បដិមាករ

រវាងពាក់កណ្តាលរជ្ជកាលរបស់ព្រះអង្គ , ខ្មែរបែក សាមគ្គីគ្នាឯងបណ្តាលអោយប្រទេសចែកជាពីរ ។ ដល់មក គ.ស. ៧៨៧ លុះបានឃើញខ្មែរមិនស្រុះស្រួលគ្នាដូច្នេះ ពួកជ្វាបួន់ក៏នាំគ្នាចូលមកលុកលុយនគរកម្ពុជាវាយយកជាចំណុះ អោយនាំសួយសារអាករទៅថ្វាយព្រះមហាក្សត្រជ្វាជារៀងរាល់ឆ្នាំ ។

## ៧- ព្រះបាទជ័យវរ្ម័នទី១

( គ.ស. ៦៦៤ ដល់ ៦៦៧ = ឰសានបុរៈ )

ព្រះមហាក្សត្រអង្គនេះ ទ្រង់បានឡើងសោយរាជសម្បត្តិបន្តអំពីព្រះបាទឰសានវរ្ម័នមកក្នុង គ.ស. ៦៦៤។ ព្រះបាទជ័យវរ្ម័នទី១ ទ្រង់បានរៀបចំប្រទេសកម្ពុជាឲ្យមានរបៀបរយល្អ ហើយថែរក្សាទឹកដីខ្មែរឲ្យនៅស្ថិតស្ថេរដែលជាកេរ្តិ៍ដំណែលរបស់ព្រះមហាក្សត្រអង្គមុនៗ ទ្រង់បានវាយដណ្តើមអំពីប្រទេសជិតខាងមក ។

ព្រះបាទជ័យវរ្ម័នទី១ ជាក្សត្រក្លាហាន អាចធ្វើអោយសត្រូវពុំហ៊ានប៉ះពាល់ព្រះនគរបានឡើយ តែក្នុងព្រះរាជពង្សាវតារពុំមានចែងថា ព្រះអង្គឡើងនឹងប្រទេស-

ណាឡើយ ។ ក្រៅពីនេះព្រះរាជជាទ្រង់បានរួបរួមអ្នកចេះដឹងទាំងឡាយឲ្យនៅជុំវិញព្រះអង្គដើម្បីជួយធ្វើការបម្រើជាតិ ។ ក្រោយពីរាជព្រះមហាក្សត្រអង្គនេះ ឯកសារប្រវត្តិសាស្ត្រយើង ក៏បាត់ដំណឹងសូន្យឈឹងអស់ ទេះវេលាជាង ១០០ ឆ្នាំ ។

# ៨- ព្រះបាទជ័យវរ្ម័នទី២

( ៨០២ - ៨៦៩ = វ្យាធបុរៈ-ភ្នំគូលែន )

រវាង គ.ស. ៨០២ មានមហាក្សត្រខ្មែរមួយព្រះអង្គ ដែលត្រូវពួកជ្វាប្លន់ចាប់នាំយកជាឈ្លើយទៅស្រុកជ្វា កាលដែលជ្វាចូលមកលុកលុយប្រទេសខ្មែរក្នុង គ.ស. ៧៨៧ នោះ បានយាងត្រឡប់មកយករាជសម្បត្តិវិញ ដោយខ្សឹងដណ្តើមយកជ័យជំនះអំពីពួកជ្វាប្លន់ ។ ព្រះអង្គមានព្រះនាមថា ព្រះបាទជ័យវរ្ម័នទី២ ព្រះមហាក្សត្រអង្គនេះទ្រង់បញ្ជាអោយឈប់នាំសួយសារអាករទៅថ្វាយស្តេចជ្វាដូចមុនទៀត។ ហើយទ្រង់លើករាជធានីពីក្រុងវ្យាធបុរៈទៅតាំងនៅឯភ្នំគូលែនវិញ ។ ទ្រង់បានសាងព្រះរាជ-

ដំណាក់មួយ ឈ្មោះប្រាសាទមហិន្ទ្រា និង ព្រះរាជវាំងមួយទៀតនៅបឹងមាលា ( ចម្ងាយជាង ៣០០ ម៉ែត្រពីភ្នំគូលែន ) ។

ដើម្បីនឹងសំដែងឫទ្ធានុភាពឲ្យគេគោរពព្រះអង្គដូចជាទេវលោក ព្រះបាទជ័យវរ្ម័នទី២ ទ្រង់ព្រះរាជបញ្ជាអោយជាងសាងព្រះរូបរបស់ព្រះអង្គប្រទាមព្រះនាមថា (( ព្រះទេវរាជា )) ។

បើទ្រង់ស្តេចយាងទៅកាន់កន្លែងណាក្តី ព្រះអង្គតែងត្រាស់បង្គាប់អោយគេយកព្រះរូបនោះទៅតាមជានិច្ច ។ បន្ទាប់មកទ្រង់បានបង្កើតឲ្យមានពួកព្រាហ្មណ៍បុរោហិតសម្រាប់ចាត់ចែងធ្វើបុណ្យថ្វាយព្រះរូប ។ ព្រះអង្គបានសាងប្រាសាទបន្ទាយឆ្មាដែលប្រកបដោយក្បូរក្បាច់ល្អឆើត ជាប្រាសាទសំខាន់ជាងគេទាំងអស់ ។ ប្រាសាទទាំងពីរនេះ យើងឃើញនៅសល់បាក់បែកដល់សព្វថ្ងៃ ។ ប្រាសាទបន្ទាយឆ្មានៅខាងជើងខេត្របាត់ដំបង ។ ប្រាសាទព្រះខ័ននៅជិតអង្គរធំ ។

# ៥- ព្រះបាទជ័យវរ្ម័នទី ៣

( គ.ស. ៨៦៩ - ៨៧៧ = ហរិហរាល័យ )

ព្រះមហាក្សត្រអង្គនេះ ជាព្រះរាជបុត្ររបស់ព្រះបាទជ័យវរ្ម័នទី ២ ។ លុះព្រះវររាជបិតាទ្រង់សោយទិវង្គត់ហើយ ព្រះអង្គក៏បានឡើយសោយរាជសម្បត្តិមក ដោយមានព្រះបរមនាមថា (( ព្រះបាទជ័យវរ្ម័នទី ៣ )) ។

ព្រះអង្គទ្រង់គង់នៅ ក្នុងក្រុងហរិហរាល័យ ។

ក្នុងរជ្ជកាលរបស់ព្រះអង្គ កិច្ចការផែនដី មិនប្រាកដថាបានចម្រើនជាងរជ្ជកាលមុនទេ តែព្រះអង្គទ្រង់អាចថែរក្សានូវវឌ្ឍនភាពគ្រប់យ៉ាងអោយនៅគង់វង់បានដូចដើម ។

ព្រះបាទជ័យវរ្ម័នទី ៣ ទ្រង់រាប់អានលទ្ធិព្រះវិស្ណុ ទ្រង់មានមហាព្រាហ្មណ៍ជាទីប្រឹក្សា ហើយទ្រង់បានសាងវត្តក្នុងសាសនាជាច្រើនថែមទៀត ។

ស្តេចគង់នៅក្នុងរាជសម្បត្តិបាន ៧ ឆ្នាំ ទើបទ្រង់សោយទិវង្គត់ ; គេថ្វាយព្រះបច្ឆាមរណនាមនៃព្រះបរមសពថា ((ព្រះវិស្ណុលោក )) ព្រោះព្រះអង្គជាអ្នកនិយមព្រះវិស្ណុ ។

# ១០- ព្រះបាទឥន្ទ្រាវរ្ម័នទី ១

( ៨៧៧ - ៨៨៩ = ភ្នំគូលែន )

ព្រះមហាក្សត្រដែលគ្រប់គ្រងរាជសម្បត្តិក្រោយពី ព្រះបាទជ័យវរ្ម័នទី ២ មកតែងយកព្រះនាម (( វរ្ម័ន ))ដាក់ខាងចុងជាដរាប ។ ព្រះរាជាទាំងនោះសុទ្ធតែជាក្សត្រសឹកសង្គ្រាមច្បាំងយកប្រទេសជិតខាងបញ្ចូលមកក្នុងព្រះនគរពង្រីកឲ្យបានធំ,នៅពេលច្បាំងឈ្នះម្តងៗ ព្រះអង្គបានរឹបយកទ្រព្យសម្បត្តិ និងចាប់សត្រូវធ្វើជាឈ្លើយយកមកឲ្យសាងប្រាសាទធំៗ ជាប្រយោជន៍ដល់ប្រទេសជាតិ ។សម័យនោះ ប្រទេសកម្ពុជាមានឫទ្ធិល្បីល្បាញពូកែណាស់ ប៉ុន្តែមានជាតិចាមស្ថិតនៅទិសខាងកើត ចូលមកច្បាំងបង្កើតកោលាហលមួយដងមួយកាលដែរ ។

ព្រះមហាក្សត្រ ដែលមានព្រះកិត្តិនាមល្បីខ្ទរខ្ទាយជាងគេគឺព្រះបាទឥន្ទ្រាវរ្ម័នទី ១ ។ ព្រះអង្គបានសាងប្រាសាទល្អៗពីរគឺប្រាសាទបាគោ នឹង បាគង ។ ក្រោយមកមានសេនារបស់ព្រះអង្គម្នាក់ បានសាងប្រាសាទមួយទៀតហៅថាប្រាសាទបាយ័ន ។

តាមសិលាចារឹកថា ព្រះបាទឥន្ទ្រាវរ្ម័នទី ១ ជាក្សត្រសឹកសង្គ្រាម តែគេពុំដឹងច្បាស់ថាព្រះអង្គច្បាំងនឹងជាតិណា ឬ ប្រទេសណាឡើយ ។

# ១១- ព្រះបាទយសោវរ្ម័ន (១)

( ៨៨៩ - ៩០៨ (២) = អង្គរធំ )

ព្រះរាជាអង្គនេះជាព្រះរាជបុត្រព្រះបាទឥន្ទ្រាវរ្ម័នទី១ ព្រះអង្គប្រកបព្រមដោយលក្ខណៈគ្រប់យ៉ាង មានព្រះរូបល្អអស្ចារ្យ ,ហើយខ្លាំងពូកែទ្រង់កាប់តែមួយព្រះខ័នដាច់-ដែក ឬ លង្ហិនជាបីកំណាត់ និងជាស្តេចមានប្រាជ្ញាលើសលែងអ្នកប្រាជ្ញទាំងពួង។

នៅដើមរជ្ជកាលរបស់ព្រះអង្គ , ទ្រង់បានចម្បាំងនឹងក្សត្រមួយអង្គដែលដណ្តើមរាជសម្បត្តិ ។ ក្នុងចម្បាំងព្រះអង្គរិះតែនឹងបរាជ័យត្រូវគេធ្វើគតហើយ តែមានសេនាបួននាក់រងឈ្នះឡើងវិញ ។

លុះសឹកសង្គ្រាមបានស្ងប់រៀបរយហើយ ទ្រង់ព្រះដំរិះសាងប្រាសាទ (( មហានគរ ឬ អង្គរធំ )) ជាបន្ទាយដ៏អាំអស្ចារ្យប្រយោជន៍ នឹង ការពារខ្មាំងសត្រូវកុំឲ្យចូលលុកលុយបានដោយងាយ ។

បន្ទាប់មក មានចាមលើកទ័ពមកច្បាំងជាច្រើនដង ប៉ុន្តែព្រះអង្គបានវាយខ្ចាត់ខ្ចាយអស់ទៅវិញ ។

---

១-ច្បាប់ខ្លះថា (ព្រះបាទយសោវរ្ម័នទី១) ។

២-ច្បាប់ខ្លះថា(៨៨៩-៩១១)

ជាពិសេស ព្រះបាទយសោវរ្ម័នបានបង្កើតអោយមានពន្ធនាគារ និង តែងច្បាប់សំរាប់ដាក់ទណ្ឌកម្មធ្ងន់ៗដល់ពួកចោរទាំងឡាយ ។ ពេលដែលព្រះអង្គទ្រង់សុរិណ្ណគតទៅប្រទេសខ្មែរយើងមានព្រំប្រទល់ធំណាស់គឺ ខាងលិចទល់-នឹង ទន្លេសាលូអង់ ក្នុងប្រទេសភូមាសព្វថ្ងៃ ខាងជើងទល់នឹងប្រទេសចិន ខាងត្បូងទល់នឹងសមុទ្ទ ហើយខាងកើតទល់នឹងសមុទ្រតុងកឹង (យួនខាងជើងសព្វថ្ងៃ) ។

## ១២-ព្រះបាទហស៌វរ្ម័នទី១

( គ.ស. ៩០៨ ...? = អង្គរធំ )

ព្រះបាទហស៌វរ្ម័នទី ១ ទ្រង់បានឡើងគ្រងរាជសម្បត្តិបន្តអំពីព្រះបាទយសោវរ្ម័នដែលជាព្រះបិតារបស់ព្រះអង្គដោយមានព្រះបរមនាមប្រាកដក្នុងព្រះរាជពង្សាវតារថា៖ (( **ព្រះបាទស្រីហស៌វរ្ម័ន** )) ។ រាជធានីដែលព្រះអង្គគង់នៅ គឺ យសោធរបុរៈ ( អង្គរធំ ) ។ ក្រោយមកព្រះអង្គបានប្រែឈ្មោះ ឲ្យហៅថា ហស៌ធរបុរៈវិញ ។

ព្រះបាទហស៌វរ្ម័ន ទ្រង់បានចាត់ការរៀបពិធីសម្ពោធប្រាសាទវិមានអាកាស ដែលស្ថាបនាឡើងតាំងពីរជ្ជកាលរបស់ព្រះបិតាព្រះអង្គម្ល៉េះ ។ ក្នុងសាវតារគេពុំបានដឹងថា

ព្រះអង្គទ្រង់សោយព្រះទិវង្គតនៅឆ្នាំណាប្រាកដទេ ប៉ុន្តែគេស្គាល់ព្រះបច្ឆា មរណនាមរបស់ព្រះអង្គថា ៖ (( ព្រះរុទ្រលោក )) ។

## ១៣- ព្រះបាទឦសានវរ្ម័នទី ២

( គ.ស. ? - ៩២៨ = អង្គរធំ )

ព្រះបាទឦសានវរ្ម័នទី ២ ជាព្រះអនុជរបស់ព្រះបាទហសិវរ្ម័នទី១ ។ ទ្រង់បានឡើងសោយរាជសម្បត្តិជាបន្តមកដោយមានព្រះបរមនាមប្រាកដថា ( ព្រះបាទស្រីឦសានវរ្ម័ន ) ហើយទ្រង់គង់នៅ រាជធានីយសោធរបុរៈដដែល ។

នៅក្នុងរជ្ជកាលរបស់ព្រះអង្គ ពុំមានព័ត៌មានអ្វីចម្លែកទេ តែគេអាចសំគាល់បានថា ទ្រង់បានគ្រប់គ្រងប្រទេសជាសុខសាន្តរហូតដល់ទ្រង់ចូល ព្រះសុវណ្ណគត ។

ព្រះបាទឦសានវរ្ម័នទី ២ ទ្រង់សោយព្រះទិវង្គតនៅ គ.ស. ៩២៨ ដោយមានព្រះបច្ឆាមរណនាមថា ៖ (( ព្រះបរមរុទ្រលោក )) ។

# ១៨- ព្រះបាទជ័យវរ្ម័នទី ៨

(៩២៨ - ៩៤២ = អង្គរធំ-កោះកែ)

ព្រះមហាក្សត្រអង្គនេះ ជាព្រះអនុជនៃព្រះបាទយសោវរ្ម័ន ព្រះអង្គបានដណ្តើមយករាជសម្បត្តិពីព្រះភគិនិយោ (១) ដែលត្រូវជាព្រះរាជបុត្ររបស់ព្រះបាទយសោវរ្ម័ន ។

ក្រោយដែលព្រះបាទយសោវរ្ម័ន ទ្រង់ព្រះសុវណ្ណគតទៅ ប្រទេសខ្មែរយើងក៏នៅមានឫទ្ធិតេស្តាចុំផ្ទើងខ្លាំងណាស់ដែរ ។ ព្រះរាជាទាំងឡាយដែលសោយរាជ្យក្រោយៗមកក៏ទ្រង់តេះតែសាងប្រាសាទបន្តទៅទៀត ។

ដោយសារសង្គ្រាមក្នុងប្រទេសកើតឡើងជាញឹកញយទើបនគរយើងថយឫទ្ធិតេស្តា ជាហេតុនាំអោយបរទេសគឺ ចាមលើកទ័ពមកច្បាំង ។ លុះដល់មក គ.ស. ៩៣០ ព្រះបាទជ័យវរ្ម័នទី ៨ ទ្រង់មិនសព្វព្រះរាជហឫទ័យគង់នៅទីក្រុងអង្គរធំ ក៏លើករាជធានីទៅតាំងនៅឯកោះកែក្នុងខេត្រកំពង់ធំសព្វថ្ងៃនេះវិញ ។ ដូច្នេះទីក្រុងអង្គរធំក៏ទុកចោលទទេ គ្មានមនុស្សនៅឡើយ ។

---

១- ភគិនិយោ = ក្មួយប្រុស ។

# ១៥- ព្រះបាទហរិវរ្ម័នទី ២

( គ.ស. ៩៤២ - ៩៤៤ = កោះកែ )

ព្រះមហាក្សត្រអង្គនេះ ជាព្រះរាជបុត្ររបស់ព្រះបាទជ័យវរ្ម័នទី ៤ និងជាព្រះរាជអនុជរបស់ព្រះបាទរាជេន្ទ្រាវរ្ម័នទី ២ ។ ព្រះអង្គបានឡើងសោយរាជសម្បត្តិបន្តពីព្រះវររាជបិតាក្នុង គ.ស.៩៤២ នៅរាជធានីកោះកែ។

បើតាមសិលាចារឹកនៅប្រាសាទព្រះឥន្ទ្រកោសិយមានសេចក្ដីថា ៖ ព្រះបាទហរិវរ្ម័នទី ២ ជាស្ដេចមានឫទ្ធានុភាពខ្លាំងក្លាណាស់ ដែលប្រជាជាតិទាំងមូលបានប្រៀបប្រដូចព្រះអង្គថា បីដូចជាដួងព្រះអាទិត្យ ឬព្រះចន្ទដែលមានពន្លឺចិញ្ចែងចិញ្ចាចនៅក្នុងព្រះរាជសន្តតិវង្សកោណ្ឌញ្ញ

ប៉ុន្តែព្រះអង្គសោយរាជ្យបានតែពីរឆ្នាំប៉ុណ្ណោះ គឺនៅគ.ស. ៩៤៤ ព្រះបាទរាជេន្ទ្រាវរ្ម័ន ដែលត្រូវជាព្រះរៀមច្បងរបស់ព្រះអង្គ ឡាំងដណ្ដើមរាជសម្បត្តិបាន ហើយឡើងសោយរាជ្យតមក ។

# ១៦- ព្រះបាទរាជេន្ទ្រាវរ្ម័នទី ២

( គ.ស. ៩៤៤ - ៩៦៨ = កោះកែ )

ព្រះបាទរាជេន្ទ្រាវរ្ម័នទី ២ ជាព្រះរាជបុត្រនៃព្រះបាទជ័យវរ្ម័នទី ៤ ។ ទ្រង់ឡើងគ្រងរាជ្យនៅកោះកែបានតែត្រឹមមួយឆ្នាំប៉ុណ្ណោះ ក៏ទ្រង់យាងត្រឡប់មកគង់នៅនគរធំវិញ ។ ព្រះអង្គបានត្រាស់ឲ្យសាងប្រាសាទរាជដ្ឋាន (១) ទេវដ្ឋាន (២) បន្ថែមជាច្រើនទៀតព្រមទាំងបានជួសជុលប្រាសាទអង្គរធំឡើងជាថ្មីទៀតផង ។

ព្រះបាទរាជេន្ទ្រាវរ្ម័នទី ២ ទ្រង់បានច្បាំងនឹងចាមជាច្រើនដង ដោយវាយយកនគរចាមដាក់ជាចំណុះ អោយនាំសួយសារអាករមកថ្វាយព្រះអង្គ ។ កាលដែលព្រះអង្គទ្រង់សុរិវណ្ណគតទៅប្រទេសខ្មែរយើងមានស្រុកចំណុះជាង ៦០ នគរ ។

---

១- រាជដ្ឋាន = កន្លែងសម្រាប់ព្រះរាជាប្រថាប់នៅ ។

២- ទេវដ្ឋាន = កន្លែងសម្រាប់ទេវតានៅ ។

# ១៧- ព្រះបាទជ័យវរ្ម័នទី ៥

( គ.ស. ៩៦៨ - ១០០២ = អង្គរធំ )

ព្រះនរបតីអង្គនេះ ជាព្រះរាជបុត្រ នៃព្រះបាទរាជេន្រ្ទាវរ្ម័នទី ២ ។ នៅក្នុងរាជ្យរបស់ព្រះអង្គ គេមិនឮពត៌មានថា ព្រះអង្គច្បាំងជាមួយប្រទេសណាទេ ។ កាលនេះមានគេគោរពបូជាព្រះពុទ្ធសាសនាច្រើនហើយដែរ ប៉ុន្តែព្រះមហាក្សត្រទាំងអស់ ទ្រង់នៅតែកាន់ព្រហ្មញ្ញសាសនា ។ គេដឹងថា សាសនាព្រះពុទ្ធផ្សាយចូលមកក្នុងរវាង ព.ស. ៩៩៣ គ.ស. ៤៥០ ។ ដល់មក ព.ស. ១០៣៣ គ.ស. ៤៩០ ទើបបានព្រះមហាក្សត្រប្រទេសយើង ទ្រង់ទទួលគោរពបូជាព្រះពុទ្ធសាសនាយ៉ាងមាំមួន ។ រីឯអ្នកជាសៃយសាសន៍ (១) ក៏បែរមកកាន់ព្រះពុទ្ធសាសនាជាច្រើនដែរ ។

នៅក្នុងកំពែងមហានគរ ជិតប្រាសាទបាយ័ន មានដំណែលព្រះពុទ្ធរូបមួយអង្គយ៉ាងធំព្រះនាមថា ព្រះពុទ្ធរូប (( គោកធ្លក )) ដែលបានសាងឡើងក្នុងរវាង ព.ស.-១៤៨៦ ត្រូវនឹង គ.ស. ៩៤៣ ។

---

១-សៃយសាសន៍ ៖ អ្នកកាន់សាសនាដទៃក្រៅពីព្រះពុទ្ធសាសនា

# ១៨- ព្រះបាទសុរិយាវរ្ម័នទី ១

( គ.ស. ១០០២ - ១០៤៩ = អង្គរធំ )

ព្រះមហាក្សត្រអង្គនេះ ត្រូវជាព្រះរាជវង្សរបស់ព្រះបាទ យសោវរ្ម័ន ។

ដោយហេតុតែកាលនោះ ស្តេចចំណុះទាំងអស់ដែលនៅតាមជួរភ្នំដងរែក និង ទន្លេមេណាម នាំគ្នាបះបោរឡើង បានជាព្រះអង្គត្រូវធ្វើសង្គ្រាមអស់ពេល ៣ ឆ្នាំ ទើបបានគ្រងរាជសម្បត្តិ ។

លុះធ្វើសង្គ្រាមជាមួយពួកស្តេចបះបោរ ទាំងនោះរួចហើយព្រះរាជាអង្គនេះទ្រង់ចងសម្ពន្ធមិត្តជាមួយ ព្រះចៅក្រុងចិន និង ស្តេចចាម ដើម្បីរួមកំលាំងការពារកងទ័ពយួនដែលវាប្រាថ្នានឹងវាយយកប្រទេសនានាដាក់ជាចំណុះ ពេលនោះ វាបានមកតាំងទីលំនៅ នៅត្រង់ដំបន់ខាងជើងប្រទេសចាម គឺត្រង់តុងកឹងសព្វថ្ងៃនេះ ។

ជាពិសេស ព្រះបាទសុរិយាវរ្ម័នទី ១ ទ្រង់បានសាងប្រាសាទពីរ គឺនៅភ្នំជីសូរ ក្នុងស្រុកបាទី ១ , នៅភ្នំសន្ទុក ១ (ខេត្តកំពង់ធំ) ។ ទ្រង់ជាក្សត្រទំនុកបំរុងព្រះពុទ្ធសាសនាណាស់ ហេតុនេះបានជាដល់ព្រះអង្គ ទ្រង់សុរគតគេថ្វាយព្រះនាមព្រះអង្គថា (ព្រះនិព្វានបាទ)។

# ១៩- ព្រះបាទឧទយាទិត្យាវរ្ម័ន

( គ.ស. ១០៤៩ - ១០៧៩ = អង្គរធំ )

ព្រះបាទឧទយាទិត្យាវរ្ម័ន ជាព្រះរាជនត្តា (១)ព្រះបាទសុរិយាវរ្ម័នទី ១ ។ ព្រះអង្គបានឡើងគ្រងរាជសម្បត្តិក្នុង គ.ស. ១០៤៩ ។

ក្នុងរជ្ជកាលនៃព្រះអង្គ ប្រទេសពុំបានសុខសាន្តទេ ព្រោះមានចម្បាំង ៤ លើក ។

ប៉ុន្តែព្រះអង្គមានទ័ពម្នាក់ជាអ្នកខ្លាំងពូកែ វាយកំចាត់ពួកខ្មាំងទាំងនោះអោយរាបទាបទៅវិញ ។

តែមិនបានប៉ុន្មានឆ្នាំ ព្រះអង្គក៏ទ្រង់ព្រះសុវណ្ណគតទៅ គឺនៅក្នុង គ.ស. ១០៧៩ ។

---

១- ព្រះរាជនត្តា ឬ នត្តោ = ចៅ ។

# ២០- ព្រះបាទហស៊ីទវរ្ម័នទី ៣

( គ.ស. ១០៧៩ - ១០៩០ = អង្គរធំ )

ព្រះបាទហស៊ីវរ្ម័នទី ៣ ជាព្រះអនុជពៅនៃព្រះបាទឧទយាទិត្យាវរ្ម័ន ទ្រង់បានឡើងសោយរាជសម្បត្តិក្នុង គ.ស. ១០៧៩ ។ ក្នុងរជ្ជកាលរបស់ព្រះអង្គ មានកើតចលាចលក្នុងប្រទេសយ៉ាងធំ ដោយសារមានចម្បាំងក្នុងស្រុកស្ទើរតែគ្រប់ដំបន់ ។ ប៉ុន្តែព្រះរាជា ទ្រង់វាយបង្ក្រាបពួកទាំងនោះរហូតទាល់តែបានសេចក្តីសុខសាន្ត-វិញ ។

កាលពី គ.ស. ១០០០ , ប្រទេសចិនកើតចំបាំងជាមួយប្រទេសយួន ។ ព្រះចៅអធិរាជចិនក៏បានផ្ញើព្រះរាជសារមកសុំកងកម្លាំងខ្មែរទៅជួយធ្វើសង្គ្រាម ។ ព្រះបាទហស៊ីវរ្ម័នទី ៣ ក៏ព្រមបញ្ជូននូវកងទ័ពខ្មែរ ទៅជួយធ្វើសង្គ្រាមការពារប្រទេសចិន ដោយហេតុព្រះអង្គបានធ្វើកិច្ចសន្យា សម្ពន្ធភាពជាមួយប្រទេសចិន ។

ព្រះបាទហស៊ីវរ្ម័នទី ៣ ទ្រង់ចូលសុវណ្ណគត នៅក្នុងឆ្នាំ ១០៩០ ។

## ២១- ព្រះបាទសុរិយាវរ្ម័នទី ២

(គ.ស. ១១១២ - ១១៦២ - រាជធានី អង្គរធំ)

ព្រះរាជាអង្គនេះជាព្រះរាជនត្តា នៃព្រះបាទធរណិន្ទ្រវរ្ម័ន ។ ព្រះអង្គបានឡើងគ្រងរាជសម្បត្តិក្នុង គ.ស. - ១១១២ ។ នៅដើមរាជ្យរបស់ព្រះអង្គ មានចម្បាំងក្នុងនគរជាយូរអង្វែងបណ្ដាលអោយស្លាប់អស់សេនាទាហាន-ជាច្រើន ។

ដល់មក គ.ស. ១១៤៥ព្រះអង្គបានលើកទ័ពទៅវាយយកនគរចាម ហើយទ្រង់ដាក់ក្សត្រខ្មែរមួយព្រះអង្គ ឲ្យគង់នៅត្រួតត្រាប្រទេសនោះ ។

បានតែ ១៤ ឆ្នាំប៉ុណ្ណោះ គឺក្នុង គ.ស. ១១៥៧ ចាមក៏រើខ្លួនយកឯករាជ្យបានវិញ ។ នៅក្នុងរយៈពេលដែលយើងមានប្រទេសចំណុះច្រើននោះ ,ប្រជារាស្ត្រខ្មែរបានសេចក្ដីសុខក្សេមក្សាន្តយ៉ាងបរិបូណ៌ ។ ព្រះអង្គបានសាងប្រាសាទមួយដ៏ល្អវិចិត្រ ឈ្មោះប្រាសាទនគរវត្តដែលល្អលើសលែងប្រាសាទនានា ។

ព្រះបាទសុរិយាវរ្ម័នទី ២ ជាព្រះមហាក្សត្រមួយព្រះអង្គមានប្រាជ្ញាឈ្លាសវៃ ចេះរបៀបគ្រប់គ្រងប្រទេសយ៉ាងប្រសើរបំផុត ។ ព្រះអង្គគោរពបូជាសាសនាទាំង

ពីរ គឺ ពុទ្ធសាសនា និង ព្រហ្មញ្ញសាសនា ដើម្បីកុំអោយប្រជារាស្ត្រឈ្លោះទាស់ទែងគ្នាក្នុងព្រះនគរ ព្រោះតែលទ្ធិសាសនានេះ ។ គឺព្រះអង្គនេះឯងហើយ ដែលប្រជារាស្ត្រខ្មែរច្រើនស្គាល់ព្រះនាមថា (( ព្រះបទុមសុរិយាវង្ស )) ។

## ២២- ព្រះបាទជ័យវរ្ម័ន ទី ៧

( ១១៦២ - ១២០១ = រាជធានីអង្គរធំ )

ព្រះរាជាអង្គនេះ ជាព្រះភគិនិយោ រួមព្រះអយ្យកា (១) និងព្រះបាទសុរិយាវរ្ម័ន ។ ព្រះអង្គបានសោយរាជសម្បត្តិក្នុង គ.ស. ១១៦២ ហើយបានវាយដណ្តើមយកប្រទេសចាម

ដាក់ជាចំណុះម្តងទៀត ដោយដាក់មហាឧបរាជខ្មែរឲ្យនៅត្រួតត្រារហូតដល់ គ.ស. ១២២០ ។

ឃើញចាមលើកទ័ពមកឡាំងជាញឹកញយដូច្នេះ,ស្តេចចំណុះឯទៀត ៗ ក៏ឆ្លៀតបះបោរដណ្តើមឯករាជ្យដែរ តែត្រូវព្រះបាទជ័យវរ្ម័ន ទី ៧ ទ្រង់បង្ក្រាបអោយរាបអស់

---

១- អយ្យកា = ជីដូន , យាយ ។

ទៅវិញ ។ ក្នុងសម័យនោះ ប្រទេសយើងមានឫទ្ធិខ្លាំងពូកែណាស់ ។ ព្រំព្រះរាជនគរ ខាងកើតទល់នឹងប្រទេសចាម (អណ្ណាមសព្វថ្ងៃ) ខាងត្បូងទល់នឹងសមុទ្រ, ខាងលិចទល់នឹងប្រទេសភូមា (ប៊ីរម៉ានីក្រោមសព្វថ្ងៃ) ខាងជើងទល់នឹងប្រទេសចិន ។

ព្រះបាទជ័យវរ្ម័ន ទី ៧, ទ្រង់បានរៀបចំកិច្ចការផែនដីអោយរឹតតែចំរើនឡើង ៗ ហើយទ្រង់ឲ្យសាងគ្រឹហឋាន និងមន្ទីរព្យាបាលរោគជាច្រើន សម្រាប់ព្យាបាលរោគប្រជាជន ។

## ២៣-ពត៌មានក្រោយរាជ្យព្រះបាទជ័យវរ្ម័នទី៧

ពត៌មានទាំងឡាយក្នុងពេលក្រោយរាជ្យព្រះបាទជ័យវរ្ម័នទី ៧ គឺចាប់តាំងពី គ.ស. ១២០១ រហូតមកដល់ គ.ស. ១៣០០ ពុំមានប្រាកដឡើយ ។ គេពុំសូវដឹងព្រះរាជសាវតារនៃ ព្រះមហាក្សត្រប្រទេសកម្ពុជាដែលសោយរាជ្យត ៗ មកនោះឡាស់លាស់ទេ ។ គេគ្រាន់តែដឹងថា ព្រះបាទឥន្ទ្រាវរ្ម័នទី ២ ទ្រង់បានឡើងសោយរាជសម្បត្តិ តពីព្រះបាទជ័យវរ្ម័នទី ៧ មកក្នុងរវាង គ.ស. ១២០១ ដល់ ១២២១ ។ តពីនោះមកទៀត គឺព្រះបាទស្រិន្ទ្រវរ្ម័ន និង ព្រះបាទជយវរមទិបរមេស្វរៈ ព្រោះ

ក្នុងពេលនោះប្រទេសកម្ពុជា កើតកោលាហលមានចំបាំង នឹងគ្នាពុំដាច់សោះ ។

សង្គ្រាម កើតឡើងព្រោះរឿងសាសនាក៏មាន រឿងនយោបាយក៏មាន ។ ប្រជាជនស្ទើរតែទាំងអស់ បានគោរពរាប់អានព្រះពុទ្ធសាសនា ។ ចាប់តាំងពី គ.ស.-១៣០០ មក ព្រះមហាក្សត្រប្រទេសកម្ពុជាលែងយកព្រះនាមវរ្ម័នធ្វើជាព្រះបរមនាមទៀតហើយ បែរមកយកព្រះនាមជាភាសាបាលីវិញ ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានលើកដំកើងព្រះពុទ្ធសាសនា ជាសាសនាសំរាប់រដ្ឋទៀតផង ។

មួយវិញទៀត , ក្នុងសម័យនោះ សៀមចេះតែលើកទ័ពចូលមកច្បាំងជាញឹកញយ ដើម្បីវាយយកនគរធំ ។ ទ្រព្យសម្បត្តិ និង មហាប្រាសាទខ្លះនៅនគរធំត្រូវវិនាស-បាក់បែកដោយសារកងទ័ពសៀម ។ ព្រះមហាឧបរាជ-ខ្មែរ ដែលនៅត្រួតត្រាឯប្រទេសចម្ប៉ា ក៏លើកទ័ពចូលមកជួយការពារប្រទេសវិញក្នុង គ.ស. ១២២០ ជាហេតុនាំអោយប្រទេសនៅក្រោមអាណាព្យាបាលនោះ បានរើខ្លួនរួចជាប្រទេសឯករាជ្យវិញចាប់តាំងពីពេលនោះមក ។

# ២៨- ព្រះបាទត្រសក់ផ្អែម

( គ.ស. ១៣២៣ - ១៣៤០ =រាជធានីអង្គរធំ )

ព្រះបាទត្រសក់ផ្អែមជាក្សត្រ ដែលសោយរាជតពីព្រះមហាក្សត្រវង្ស (( វរ្ម័ន )) មក ។ មុននឹងឡើងគ្រង-រាជ្យ ព្រះអង្គមានត្រកូលជារាស្ត្រសាមញ្ញហើយជាអ្នកដាំត្រសក់ ។ សម័យថ្ងៃមួយ តាត្រសក់ផ្អែមបានបេះផ្លែត្រសក់ផ្អែមយកទៅថ្វាយស្តេច ។ ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យ ក៏ទ្រង់ប្រទានលំពែងមួយ អោយទុកសំរាប់ការពារចំការត្រសក់របស់គាត់ ។ មានយប់មួយនោះព្រះមហាក្សត្រទ្រង់ស្តេចយាងទៅចំការ ដើម្បីល្បងមើលការចាំចំការរបស់តាត្រសក់ផ្អែម ។ ជួនជាម្ចាស់ចំការច្រឡំ ក៏ពួយមួយលំពែងត្រូវព្រះរាជាក្ស័យព្រះជន្មទៅ ។

តាត្រសក់ផ្អែមបានឡើងគ្រងរាជ្យពី គ.ស. ១៣២៣ នោះមកដោយមានព្រះនាមថា (ព្រះបាទត្រសក់ផ្អែម) ។

លុះដល់មក គ.ស. ១៣៤០ ព្រះអង្គក៏ទ្រង់ព្រះសុវណ្ណគត ហើយរាជសម្បត្តិក៏ត្រូវព្រះរាជវង្សរបស់ព្រះអង្គគ្រប់គ្រងតរៀងមក ។

# ២៥- ព្រះនិព្វានបាទ

(គ.ស. ១៣៤០ - ១៣៤៦ = រាជធានីអង្គរធំ)

ព្រះមហាក្សត្រអង្គនេះ ជាព្រះរាជបុត្រច្បងរបស់ព្រះបាទត្រសក់ផ្អែម ។ ព្រះអង្គបានឡើងគ្រងរាជសម្បត្តិបន្តពីព្រះវរបិតាមកក្នុងឆ្នាំ ១៣៤០ ។

នៅក្នុងរជ្ជកាលរបស់ព្រះអង្គ នគរស្ថិតនៅក្នុងសន្តិភាពជាសុខសាន្ត ដោយព្រះអង្គបានចងសម្ពន្ធមេត្រីភាពជាមួយប្រទេស លាវ , សៀម , យួន , (តុងកឹង) និងចម្ប៉ា ។

ព្រះបាទនិព្វានបាទ ទ្រង់សោយរាជសម្បត្តិបាន ៥ឆ្នាំប៉ុណ្ណោះ ក៏ទ្រង់ព្រះសុវណ្ណគតទៅនៅក្នុង គ.ស. -១៣៤៦ ។

# ២៦-ព្រះបាទសិទ្ធានរាជា

(គ.ស. ១៣៤៦ = រាជធានីអង្គរធំ)

ព្រះមហាក្សត្រអង្គនេះ ជាព្រះអនុជរបស់ ព្រះនិព្វានបាទ ។ ព្រះអង្គបានឡើងសោយរាជសម្បត្តិបន្តពីព្រះរៀម ក្នុង គ.ស. ១៣៤៦ ដោយយកអង្គរធំដដែលជារាជធានី ។

ព្រះបាទសិទ្ធានរាជា ទ្រង់ដណ្តើមរាជសម្បត្តិអំពីព្រះភគិនិយោទាំងពីរបស់ព្រះអង្គ ដែលជាព្រះរាជបុត្ររបស់ព្រះបាទនិព្វានបាទ ។

ប៉ុន្តែព្រះអង្គ ទ្រង់សោយរាជសម្បត្តិបានតែ ៦ ឆ្នាំ ក៏សុវណ្ណគតទៅ គឺនៅក្នុង គ.ស. ១៣៤៦ នោះឯង ។

## ២៧- ព្រះបាទស្រីលំពង្សរាជា

(គ.ស. ១៣៤៧ - ១៣៥៣ = រាជធានីអង្គរធំ)

ព្រះស្រីលំពង្សរាជា ត្រូវជាព្រះរាជនត្តានៃព្រះបាទ-ត្រសក់ផ្អែមនិងត្រូវជាព្រះរាជបុត្រនៃព្រះបាទសិទ្ធានរាជា ទ្រង់ឡើងសោយរាជសម្បត្តិក្នុង គ.ស. ១៣៤៧ ។ នៅក្នុងរាជ្យព្រះអង្គ ស្តេចសៀមនាមឧតុងបានលើកទ័ពមកឡោមព្រាទ្ធាយកនគរធំ ។ ចម្បាំងនេះយូរណាស់ លុះចូលមកដល់ គ.ស. ១៣៥៣ ព្រះបាទស្រីលំពង្សរាជា ទ្រង់ប្រឈួនរោគចូលសុវណ្ណគតទៅ ។

ព្រះស្រីសុរិយោទ័យជាព្រះអនុជ ក៏ទ្រង់រងសង្គ្រាមឡើង ។ ប៉ុន្តែសៀមទំលាយទ្វារពីខាងបាន , ព្រះស្រី-សុរិយោទ័យ ក៏ទ្រង់សុវណ្ណគតទៅទៀត នៅ គ.ស. - ១៣៥៣ ដដែលនោះ ។ គឺក្នុងពេលនោះហើយ ដែល

សៀមលុកលុយរើយកមហាសម្បត្តិអាណាចក្ររស់ ហើយ ផែមទាំងចាប់ខ្មែរប្រហែល ១០.០០០ នាក់ បញ្ជូនជាឈ្លើយទៅក្រុងទេពផង ។ ប៉ុន្តែគ្រឿងមកុដភណ្ឌសំរាប់រាជ្យសៀមយកទៅមិនបានទេ ព្រោះពួកបារគូបណ្តេញចេញមិនរួច ។ សៀមតាំងនៅនគរធំជាង ៤ឆ្នាំ ហើយចាត់នាម៉ឺនសៀមឲ្យត្រួតត្រាខេត្តខ្មែរខ្លះផង ពី គ.ស.- ១៣៥៣ ដល់ គ.ស. ១៣៥៧ ។

## ២៨- ព្រះបាទស្រីសុរិយោទ័យ

( គ.ស. ១៣៥៣ )

ព្រះបាទស្រីសុរិយោទ័យ ជាព្រះអនុជរបស់ ព្រះបាទស្រីលំពង្សរាជា ។ ព្រះបាទស្រីសុរិយោទ័យ ជាមហា-ឧបរាជក៏បន្តសឹកសង្គ្រាមជំនួស ព្រះស្រីលំពង្សរាជាតមក.

សម័យនោះ កងទ័ពប្រទេសសៀមបានវាយទម្លាយទ្វារព្រះរាជវាំងនគរធំពីខាងកើតចូលមកបាន ។ ព្រះស្រី-សុរិយោទ័យ ទ្រង់ប្រយុទ្ធតស៊ូ ទាល់តែផុតសមត្ថភាពក្ស័យព្រះជន្ម ក្នុងទីសមរភូមិនា គ.ស. ១៣៥៣ នោះ ។

កងទ័ពសៀមបានរុករានយកទ្រព្យសម្បត្តិ និង ចាប់យកប្រជាជនខ្មែរធ្វើជាឈ្លើយសង្គ្រាមប្រមាណ ១ ម៉ឺន

នាក់អោយដឹកជញ្ជូនទ្រព្យសម្បត្តិទាំងនោះ យកទៅប្រទេសវា ។ ឯគ្រឿងមកុដភណ្ឌពួកបាគូរបរោហិតបានបណ្តោះចេញមិនរួច ។

សម័យនោះ សៀមបានត្រួតត្រាប្រទេសកម្ពុជាអស់រយៈវេលា ៤ ឆ្នាំគឺពី គ.ស. ១៣៥៣ ដល់ ១៣៥៧ ។

## ២៩-ព្រះបាទស្រីសុរិយោវង្សទី១

(គ.ស. ១៣៥៧ - ១៣៦៦ = អង្គរធំ)

ព្រះបាទស្រីសុរិយោវង្សទី ១ ជាព្រះភគិនិយោរបស់ព្រះស្រីសុរិយោទ័យ និង ព្រះស្រីលំពង្សរាជា ។ ក្នុងពេលដែលព្រះបិតុលា (១) ទាំងពីរព្រះអង្គ កំពុងធ្វើសង្គ្រាមនឹងសៀម ព្រះអង្គទ្រង់ស្តេចយាងទៅកេណ្ឌសេនារេហ៍ពលរហូតដល់ស្រុកលាវ, លុះដល់ គ.ស. ១៣៥៧ ព្រះអង្គក៏លើកទ័ពមកវាយកំចាត់សៀមចេញពី នគរធំ - ហើយទ្រង់ឡើងសោយរាជសម្បត្តិដោយបានទទួលរាជាភិសេក ជាព្រះមហាក្សត្រអម្ចាស់ផែនដីក្នុង ឆ្នាំ ១៣៥៧ នោះ ។

---

១ បិតុលា = ឪពុកមា ។

ក្នុងរជ្ជកាលរបស់ព្រះអង្គ ព្រំប្រទេសកម្ពុជាយើង-ខាងជើងរហូតដល់ស្ពានខ្សាច់គោកខណ្ឌ (សព្វថ្ងៃនៅនាដែនខុប៊ុន) ខាងលិចតាំងពីខេត្តនាងរុងអង្គរាជ(កូរ៉ាត) រហូតដល់ឈូងសមុទ្រសៀម ។

ខាងកើតដល់ដុងណៃ (សព្វថ្ងៃហៅថាណូណៃក្នុង-ខេត្តបារៀ នៃដែនកូសាំងស៊ីន ) ។

## ៣០- ព្រះបាទបរមរាជា

(គ.ស. ១៣៦៦ - ១៣៧៣ = រាជធានីអង្គរធំ)

ព្រះបាទបរមរាជាព្រះរាជបុត្រនៃព្រះបាទស្រីលំពង្ស-រាជា ។ ព្រះអង្គបានត្រូវសមាជិកព្រះរាជវង្សានុវង្សនិងគណៈរដ្ឋមន្ត្រីតែងតាំងឡើងជាព្រះមហាក្សត្រក្នុង គ.ស. ១៣៦៦ ។

ពត៌មានសម្រាប់រាជ្យរបស់ព្រះអង្គ ពង្សាវតារយើងពុំចែងច្បាស់ឡើយ ។ តែពត៌មានខ្លះបញ្ជាក់ថា ព្រះបាទបរមរាមាបានចងសម្ពន្ធមេត្រីជាមួយ ព្រះចៅអធិរាជចិននៃព្រះវង្ស មិង , ហុង-វូ ។ ប្រទេសបានសុខសាន្ត។

ព្រះបរមរាមាទ្រង់សោយរាជ្យបាន ៧ ឆ្នាំ ហើយទ្រង់ប្រឈួន រួចព្រះសុវណ្ណគតទៅ នៅក្នុង គ.ស. - ១៣៧៣ ។

# ៣១-ព្រះបាទធម្មាសោក

(គ.ស. ១៣៧៣ - ១៣៩៤ = រាជធានីអង្គរធំ)

ព្រះបាទធម្មាសោក ជាព្រះរាជបុត្រនៃព្រះស្រីលំពង្សរាជានិងជាព្រះអនុជព្រះបាទបរមរាមា ។ ព្រះអង្គបានឡើងគ្រងរាជសម្បត្តិក្នុង គ.ស. ១៣៧៣ ។

នៅចុងរជ្ជកាលព្រះអង្គរវាង គ.ស. ១៣៩៤ សៀមលើកទ័ពមកព័ទ្ធនគរធំម្តងទៀត ឡោំងគ្នាអស់រយៈវេលា ៧ ខែ បណ្តាលអោយស្លាប់អស់កងទាហានជាច្រើន តែវាពុំអាចវាយយកនគរធំបានឡើយ ។

ឃើញដូច្នេះ សៀមក៏ប្រើឧបាយកលឃោរឃៅមួយយ៉ាងសំខាន់ ដោយបង្គាប់ឲ្យមេទ័ពវាទាំង ៤ នាក់រត់ចូលទៅក្រាបបង្គំគាល់ ថ្វាយខ្លួនបូជាជីវិតចំពោះ ព្រះមហាក្សត្រខ្មែរ ។ ចារបុរសសៀមទាំង ៤ នាក់ ស៊ើបការអាថ៌កំបាំងរបស់ខ្មែរដឹងអស់គ្មានសល់ចន្លោះអ្វី ។ មិនតែប៉ុណ្ណោះមាន មេទ័ពខ្មែរពីរនាក់ទៀតរួមគំនិតក្បត់នឹងសៀមក្បត់ជាតិឯង ។

ដោយហេតុនេះ សៀមក៏អាចទំលាយទ្វារបន្ទាយនគរធំ ពីខាងលិចបាន រួចចូលមកឡោំងកាប់ចាក់គ្នាក្នុងក្រុងយ៉ាងសម្បើម ។ ព្រះបាទធម្មាសោក ក៏ទ្រង់សុគតក្នុង-

សង្គ្រាមនោះទៅ នៅក្នុង គ.ស. ១៣៩៤ នោះឯង ។

សៀមបានឱកាស ចូលមកនៅត្រួតត្រាប្រទេសខ្មែរមួយលើកទៀត ។ ប៉ុន្តែមិនយូរប៉ុន្មានទេ វាដកខ្លួនថយចេញទៅស្រុកវាវិញ ព្រោះមានចលាចលនៅប្រទេសវា។

## ៣២-ព្រះបាទស្រីសុរិយោវង្សទី២

(គ.ស. ១៤០១ - ១៤១៧ = រាជធានីអង្គរធំ)

ព្រះមហាក្សត្រអង្គនេះ ជាព្រះរាជបុត្រនៃព្រះមហាឧបរាជ ស្រីសុរិយោទ័យ ដែលសុគតក្នុងសង្គ្រាមកាលសៀមវាយយកនគរធំលើកដំបូង ។

ក្នុងពេលដែលស្រុកសៀមមានកើតចលាចល សៀមដែលតាំងនៅនគរធំក៏ដកទ័ពថយទៅវិញ ។

ប្រជារាស្ត្រខ្មែរ នាំគ្នាថ្វាយរាជសម្បត្តិទៅ ព្រះស្រីសុរិយោវង្សទី ២ ដែលមានព្រះជន្ម ៤៣ ព្រះវស្សានៅ គ.ស. ១៤០១ ។

ព្រះអង្គទ្រង់ឡើងគ្រងរាជ្យបាន ១៦ វស្សាព្រះជន្ម ៥៦ គឺ ដល់មក គ.ស. ១៤១៧ ក៏ទ្រង់ស្តេចយាងចូលសុវណ្ណគតទៅ ។ ព្រះបាទស្រីសុរិយោវង្សទី ២ មាន

ព្រះរាជបុត្រមួយព្រះអង្គ ព្រះនាមព្រះពញាយ៉ាត ព្រះជន្ម បាន ១៧ វស្សា ។

## ៣៣- ព្រះបរមសុខា

(គ.ស. ១៤១៧ - ១៤២០ = រាជធានីអង្គរធំ)

ព្រះបរមសុខា ជាព្រះភគិនិយោរបស់ព្រះស្រីសុរិយោវង្សទី ២ ។ កាលដែលព្រះស្រីសុរិយោវង្សទី ២ ទ្រង់ព្រះសុវណ្ណគតទៅ ព្រះអង្គក៏ឡើងគ្រងរាជ្យជាដំណាមក នៅ គ.ស. ១៤១៧ ។ នៅចុងរាជ្យរបស់ព្រះអង្គ គឺ រវាង គ.ស. ១៤២០ សៀមបានលើកទ័ពមកព័ទ្ធនគរធំទៀត ។

កាលនោះមានចំបាំងកាប់ចាក់គ្នាក្នុងនគរយ៉ាងសំបើមអស្ចារ្យណាស់ ។

ព្រះបរមសុខាទ្រង់តស៊ូនឹងសង្គ្រាមរហូតដល់ក្ស័យព្រះជន្ម ។ បានឱកាសហើយសៀមក៏មកតាំងនៅនគរធំ ។ ដល់មក គ.ស. ១៤២១ទើបព្រះបាទពញាយ៉ាតទ្រង់វាយកំចាត់ចេញទៅវិញអស់ ហើយទ្រង់ឡើងសោយរាជ្យតរៀងមក ។

# ៣៨- ព្រះបាទពញាយ៉ាត

(គ.ស. ១៤២១-១៤៦២=អង្គរធំ-ទួលបាសាន-ចតុមុខ)

ព្រះបាទពញាយ៉ាត ជាព្រះរាជបុត្រនៃព្រះបាទស្រី-សុរិយោវង្សទី២ ។ បានជាព្រះអង្គមិនឡើងសោយរាជ្យកាលដែលព្រះបិតាទ្រង់សុគតទៅនោះ ព្រោះទ្រង់នៅ-មានព្រះជន្មក្មេងពេក ។

លុះដល់មក គ.ស. ១៤២១ ព្រះអង្គទ្រង់វាយកំចាត់សៀមចេញពីនគរបាន ហើយទ្រង់ឡើងគ្រងរាជ្យ គង់នៅរាជធានីអង្គរធំដដែលនោះ បានចំនួនជិត ៥ឆ្នាំទើបទ្រង់ឃើញយល់ថា នៅជិតសៀមពេក ក៏ទ្រង់ផ្លាស់រាជធានីពីអង្គរធំមកតាំងនៅទួលបាសាន ក្នុងស្រុកស្រីសន្ធរ-សព្វថ្ងៃវិញ ។

គង់នៅបាន ១ ឆ្នាំ ទួលបាសានត្រូវទឹកជំនន់លិចក្នុងរដូវវស្សា ព្រះអង្គក៏ផ្លាស់រាជធានីមកតាំងនៅ ទន្លេចតុ-មុខ ( ភ្នំពេញ ) វិញទៀត ។ ព្រះពញាយ៉ាតទ្រង់គ្រងរាជ្យបាន ១២ ឆ្នាំ ទើបទ្រង់ទទួលរាជាភិសេកដោយមានព្រះបរមនាម ថា ((ព្រះបរមរាជាធិរាជរា - មាធិបតី )) ។ ដើម្បីជាសន្តិសុខដល់ប្រទេស ព្រះអង្គ

បានចាត់អោយរាជទូតនាំសួយ ជាដំរី និង វត្ថុមានតំលៃផ្សេង ៗ យកទៅថ្វាយស្តេចក្រុងចិន ដើម្បីចងស្ពានមេត្រីជាសម្ពន្ធមិត្ត ។

## ៣៥-ព្រះនារាយណ៍រាមាធិបតី

(គ.ស. ១៥៦២ - ១៥៦៧ =ចតុមុខ)

ព្រះមហាក្សត្រអង្គនេះ ជាព្រះរាជបុត្រច្បងនៃព្រះបាទសម្តេចព្រះពញាយ៉ាត ។

លុះអស់រាជ្យព្រះវរបិតាទៅ ព្រះអង្គក៏គ្រប់គ្រងរាជសម្បត្តិតមកនៅក្នុង គ.ស. ១៥៦២ ។

គេឮថាទ្រង់បានសាងចេតិយកំពូលប្រាំ ដោយមានកំពស់ ១២០ ម៉ែត្រ រវាង ១ ខែប៉ុណ្ណោះ តែមិនដឹងជានៅកន្លែងណាឡើយ ។

ព្រះនារាយណ៍រាមាទ្រង់សោយរាជ្យបាន ៥ឆ្នាំក៏ទ្រង់ព្រះសុរិវណ្ណគតទៅក្នុង គ.ស. ១៥៦៧ ។ ទ្រង់មានព្រះរាជបុត្រមួយព្រះអង្គនាមថា ព្រះស្រីសុរិយោទ័យ ។

ព្រះមហាក្សត្រអង្គក្រោយ បានយកព្រះអដ្ឋិធាតុរបស់ព្រះអង្គ បញ្ចុះក្នុងចេតិយវត្តភ្នំ ខាងទិសពាយ័ព្យទុកជាទីគោរពរហូតដល់សព្វថ្ងៃ ។

# ៣៦- ព្រះស្រីរាជា

( ១៤៦៧ - ១៤៧៤ = អមរបុរី )

ព្រះស្រីរាជា ជាព្រះរាជអនុជរបស់ព្រះនារាយណ៍រាមាធិបតី ។ ព្រះអង្គបានឡើងសោយរាជសម្បត្តិ ក្នុងព្រះជន្មាយុ ១៩ ព្រះវស្សា ក្នុង គ.ស. ១៤៦៧ ។

ទ្រង់ឡើងសោយរាជ្យបានតែ ១ ឆ្នាំ ស្រាប់តែព្រះរាជបុត្ររបស់ព្រះនារាយណ៍រាមាធិបតី ព្រះនាមស្រីសុរិយោទ័យបះបោរឡើង លើកទ័ពមកច្បាំងដណ្ដើមរាជសម្បត្តិអំពីព្រះអង្គ ។ ជួនជាពេលនោះ សៀមលើកទ័ពមករុករានអាណាខែត្រខាងលិច គឺអង្គររាជ, អង្គរ និងចន្ទបុិន,ព្រះស្រីរាជាក៏ស្ដេចលើកទ័ពទៅទប់ទល់នឹងសៀមទុកការៈតចំបាំងជាមួយព្រះស្រីសុរិយោទ័យទៅ,ព្រះអនុជរបស់ព្រះអង្គទ្រង់ព្រះនាមព្រះធម្មោរាជាវិញ ។

លុះព្រះអង្គទ្រង់បង្ក្រាបសៀមរាបទាបហើយ ទ្រង់ក៏ត្រឡប់មកគ្រងរាជសម្បត្តិវិញ ។ ប៉ុន្តែព្រះធម្មោរាជាមិនព្រមថ្វាយឡើយ ។ ដូច្នេះ ប្រទេសកម្ពុជាត្រូវចែកជាបីចំណែក ដោយមានក្សត្របីព្រះអង្គគ្រងរាជសម្បត្តិ ព្រះស្រីរាជាទ្រង់គង់នៅក្រុងអមរបុរី ( ស្រុកបរិបូរ ) ; ព្រះធម្មោរាជាគង់នៅក្រុងចតុមុខ ; ឯព្រះស្រីសុរិយោទ័យ

ទ្រង់គង់នៅរាជធានីស្រីសន្ធរ ។ ប៉ុន្តែបានតែ ៣ ឆ្នាំប៉ុណ្ណោះ ព្រះធម្មោរាជាបានពឹងសៀមឲ្យមកជួយ ដើម្បីផ្ដាច់យកនគរទាំងមូលមកលើព្រះអង្គតែមួយអង្គឯង ។ សៀមក៏មកពទ្ធអញ្ជើញព្រះស្រីរាជា និង ព្រះស្រីសុរិយោទ័យ នាំយកទៅប្រទេសវាអស់ទៅ ។ ព្រះធម្មោរាជាក៏ឡើងគ្រប់គ្រងរាជ្យជាម្ចាស់ផែនដីប្រទេសកម្ពុជា ទាំងបីចំណែក ក្នុង គ.ស. ១៤៧៤ តរៀងមក ។

លុះទ្រង់លែងបារម្ភហើយ ព្រះអង្គក៏ចាត់ចែងគ្រប់គ្រងនគរប្រកបនូវព្រះរាជធម៌រហូតដល់ឆ្នាំ ១៤៩៨ ក៏ទ្រង់សុវណ្ណគតទៅ ។

# ៣៧-ព្រះបាទស្រីសុរិយោទ័យ

(គ.ស. ១៤៦៨ - ១៤៧៤ =ស្រីសន្ធរ)

ព្រះបាទស្រីសុរិយោទ័យជាព្រះរាជបុត្ររបស់ព្រះបាទនារាយណរាមាធិបតី ដែលត្រូវជាព្រះភគិនិយោរបស់ព្រះបាទស្រីរាជា ។ ព្រះអង្គទ្រង់លើកទ័ពមកច្បាំងដណ្ដើមយករាជសម្បត្តិអំពីព្រះបិតុលោរបស់ព្រះអង្គ គឺព្រះបាទស្រីរាជា ហើយប្រកាសថា ( ព្រះអង្គជាព្រះមហាក្សត្រនៃប្រទេសកម្ពុជា ) ក្នុង គ.ស. ១៤៦៨ ។

នៅក្នុងឆ្នាំដែលព្រះអង្គច្បាំងដណ្តើមរាជសម្បត្តិ អំពីព្រះបិតុលានេះ ពួកសៀមក៏ចូលមកលុកលុយអាណាខេត្តកម្ពុជាដែរ ។ ដូច្នេះព្រះស្រីរាជាក៏ទ្រង់ប្រគល់ភារៈថ្វាយព្រះនុជរបស់ព្រះអង្គ ដើម្បីធ្វើចម្បាំងតយុទ្ធជាមួយនឹង-ព្រះបាទស្រីសុរិយោទ័យ នៅក្នុងប្រទេស ឯព្រះអង្គទ្រង់លើកទ័ពទៅច្បាំងទប់ទល់នឹងកងទ័ពសៀម ។

ប្រទេសកម្ពុជាសម័យនោះ កើតកោលាហល ។ ប្រ-ជារាស្ត្ររងទុក្ខវេទនាជាខ្លាំង ។

## ៣៨- ព្រះធម្មរាជា (១)

(គ.ស. ១៤៦៨ - ១៤៩៨ = ចតុមុខ)

ព្រះបាទធម្មរាជា ជាព្រះរាជបុត្រពៅរបស់ព្រះបាទ-នារាយណ៍រាមាធិបតី ។

ក្នុងពេលដែលព្រះបាទស្រីរាជា មានជ័យជំនះលើកងទ័ពសៀម ហើយទ្រង់ស្តេចយាងនិវត្តចូលមកក្នុងព្រះនគរវិញនោះ ព្រះបាទធម្មរាជា ក៏ទ្រង់ប្រកាសព្រះអង្គថា ជាព្រះមហាក្សត្រនៃប្រទេសកម្ពុជាដែរក្នុង គ.ស. ១៤៦៨ .

ប្រទេសកម្ពុជាក្នុងសម័យនោះ ត្រូវមានព្រះមហាក្ស-

---

១· ច្បាប់ខ្លះថា ៖ ព្រះធម្មោរាជា។

ត្រ បីព្រះអង្គ ។ ដូច្នេះប្រទេសក៏ត្រូវបែងចែកជាបីផ្នែកដែរ គឺព្រះបាទស្រីរាជាទ្រង់គ្រប់គ្រងនៅក្រុងអមរបុរី ( ស្រុកបរិបូរ ) ; ព្រះបាទស្រីសុរិយោទ័យ សោយរាជ្យនៅរាជធានីស្រីសន្ធរ ៈ ព្រះបាទធម្មរាជាទ្រង់គង់នៅក្រុងចតុមុខ ។

៣ ឆ្នាំ ក្រោយមកព្រះបាទធម្មរាជាទ្រង់ពឹងសៀមឲ្យជួយ វាយដណ្ដើមយកប្រទេសកម្ពុជាទាំងមូល ។ ទ័ពសៀមក៏បានច្បាំងនឹងព្រះបាទស្រីរាជា និង ព្រះបាទសុរិទ័យ ហើយចាប់ព្រះមហាក្សត្រទាំងពីរព្រះអង្គនេះ យកទៅទុកនៅឯស្រុកសៀម ។

ដូច្នេះ គ.ស. ១៤៧១ ព្រះបាទធម្មរាជាទ្រង់ឡើងសោយរាជសម្បត្តិ លើប្រទេសកម្ពុជាទាំងមូល ។

ព្រះបាទធម្មរាជា ជាព្រះមហាក្សត្រមួយព្រះអង្គដែលទ្រង់មានវិជ្ជាជ្រៅជ្រះ ហើយទ្រង់គ្រប់គ្រងផែនដីដោយទសពិធរាជធម៌ ។ ព្រះអង្គបានសាងប្រាសាទមួយនៅភ្នំសន្ទុក ( ក្នុងខេត្រកំពង់ធំ ) ។

ព្រះបាទធម្មរាជាទ្រង់សុវណ្ណគតក្នុង ឆ្នាំ ១៤៩៨ ។

# ៣៩- ព្រះបាទស្រីសុគន្ធបទ

(គ.ស. ១៤៩៨ - ១៥០៥ =ចតុមុខ-ទួលបាសាន)

ព្រះបាទស្រីសុគន្ធបទ ជាព្រះរាជបុត្រច្បងនៃព្រះបាទធម្មោរាជា ។ ព្រះអង្គបានឡើងសោយរាជសម្បត្តិតពីព្រះវរបិតាមកនៅ គ.ស. ១៤៩៨ ។

លុះបានទទួលរាជាភិសេកហើយ ព្រះអង្គទ្រង់យាងទៅគង់នៅទួលបាសាន ជារាជធានីដំណែលចាស់នៃព្រះអ-យ្យកោ (ពញាយ៉ាត) វិញ ទុកព្រះអនុជព្រះនាមអង្គ-ចន្ទអោយគង់នៅចតុមុខ ។

ក្នុងរាជ្យរបស់ព្រះអង្គ មានបះបោរមួយយ៉ាងធំ ហៅថា ( បះនាយកន ) ។ នាយកនជាសេនាជំនិតរបស់ព្រះអង្គមានចិត្តក្បត់ បានរត់ទៅបញ្ចុះបញ្ចូលរាស្ត្រជាកងទ័ពមកច្បាំងនឹងម្ចាស់ផែនដី ហើយធ្វើគុតព្រះបាទស្រី-សុគន្ធបទបាន រួចតាំងខ្លួនជាស្តេចសោយរាជ្យបាន ១០ ឆ្នាំ គឺពី គ.ស. ១៥០៥ ដល់ ១៥១៥ ដោយមានព្រះនាមថា ( ព្រ្លួងព្រះស្តេចកន ) ។

## ៤០- ព្រះបាទអង្គចន្ទទី ១

(១៥១៥ - ១៥៥៥ = ចតុមុខ-លង្វែក)

ព្រះបាទអង្គចន្ទ ជាព្រះរាជបុត្រនៃព្រះបាទធម្មោរាជា និង ត្រូវជាព្រះអនុជនៃព្រះបាទស្រីសុគន្ធបទ ។ ក្នុងពេលដែលស្ដេចកនធ្វើសង្គ្រាមជាមួយ ព្រះស្រីសុគន្ធបទ ព្រះអង្គចន្ទទ្រង់ភៀស ព្រះអង្គទៅគង់ឯប្រទេសសៀម លុះជ្រាបដំណឹងថា ស្ដេចកនធ្វើគតព្រះរៀមបានហើយ ទ្រង់បានត្រឡប់មកមាតុប្រទេសវិញ ធ្វើសង្គ្រាមជាមួយស្ដេចកន រហូតដល់មានជ័យជំនះ ដោយពិឃាតស្ដេចកនបានក្នុងបន្ទាយស្រឡប់ពិជ័យ ( ស្រុកត្បូងឃ្មុំ )ហើយ បានគ្រងរាជ្យតមកក្នុង គ.ស. ១៥១៥ ។

ក្រោយដែលទ្រង់បានសោយរាជ្យហើយ សៀមរកឧបាយកលបង្កើតសង្គ្រាម ។ វាលើកទ័ពមកច្បាំងពីរដង គឺ ក្នុងឆ្នាំ ១៥២៨ ម្ដង និងក្នុងឆ្នាំ ១៥៣៣ ម្ដង ប៉ុន្តែត្រូវបរាជ័យជាដរាបដល់សៀមបាក់ទ័ពទៅស្រុកវិញអស់ហើយ ក្នុងឆ្នាំ ១៥២៨ ព្រះបាទអង្គចន្ទទ្រង់លើករាជធានី មកតាំងនៅលង្វែកវិញ ។ ទ្រង់គោរពព្រះពុទ្ធសាសនា ប្រកបដោយព្រះទ័យមេត្តាករុណាតែងចែកទានដល់អ្នកក្រីក្រ ។ ជាពិសេស ទ្រង់សង់វត្តអារាមជាច្រើន

ព្រមទាំងមន្ទីរព្យាបាលរោគ ។ ព្រះអង្គចន្ទជាស្ដេចក្លាហានប្រកបដោយបុទ្ធានុភាពខ្លាំងពូកែអស្ចារ្យ ទ្រង់សោយរាជ្យបាន ៤០ ឆ្នាំ ហើយទ្រង់ព្រះសុវណ្ណគតក្នុង គ.ស. ១៥៥៥ ដោយទុកព្រះកិត្តិយសដ៏ក្រអូបដល់ ព្រះរាជពង្សាវតារខ្មែរ ។

## ៤១-ព្រះបាទសម្ដេចព្រះបរមិន្ទរាជា

(គ.ស. ១៥៥៥ - ១៥៦៧ = លង្វែក)

ព្រះបាទសម្ដេចព្រះបរមិន្ទរាជា ជាព្រះរាជបុត្រព្រះបាទអង្គចន្ទទី ១ ។ មុននឹងព្រះបវរបិតាទ្រង់សុវណ្ណគតព្រះអង្គឡើងជាអគ្គស្នងការជំនួសបីឆ្នាំ ។ ដល់ គ.ស. ១៥៥៥ ក្នុងព្រះជន្មាយុ ៤៤ ព្រះវស្សា ទើបទ្រង់បានទទួលរាជាភិសេកពេញកិត្តិយស ។ ព្រះអង្គគង់នៅរាជធានីលង្វែកដដែល ។

កាលដើមរាជ្យព្រះអង្គ ក្នុង គ.ស. ១៥៥៧ ជាតិភូមាលើកទ័ពមកវាយប្រទេសសៀម ព្រះអង្គក៏ឆ្លៀតឱកាសនោះ លើកទ័ពទៅវាយប្រទេសសៀមដណ្ដើមអាណាខេត្តចន្ទបុរី, នគររាជ ជាដើម ហើយតាំងនាយទាហានខ្មែរ

ឲ្យនៅត្រួតត្រាផ្ទៃទាំងខេត្តទាំងនោះ ។ ទ្រង់បានកៀរយកគ្រួសារខ្មែរចំនួន ៧០.០០០ នាក់មកប្រទេសកម្ពុជាវិញទៀតផង ។

ដល់ គ.ស. ១៥៦០ ព្រះមហាក្សត្របានច្បាំងឈ្នះជាតិលាវទៀត ។ ទ្រង់ចាប់លាវជាឈ្លើយបានច្រើនពាន់នាក់ដាក់ឲ្យនៅក្នុងស្រុកបារាយណ៍ខេត្តកំពង់ធំសព្វថ្ងៃ និង ក្នុងស្រុកជើងព្រៃ ខេត្រកំពង់ចាម ។

ក្រោយមកទៀតរវាង គ.ស. ១៥៦២ សៀមលើកទ័ពមកវាយកំចាត់ទាហានខ្មែរ ដែលនៅត្រួតត្រាលើខេត្តទើបនឹងដណ្តើមបាននោះ ។ ព្រះបរមិន្ទរាជា លើកទ័ពទៅតយុទ្ធជាប់ជាអង្វែងឆ្នាំ ទើបសៀមសុំចុះព្រមជានឹងគ្នាដោយធ្វើសន្ធិសញ្ញាជារាជមេត្រីភាព នៅក្នុង គ.ស. ១៥៦៧ ។

ព្រះបរមិន្ទរាជាទ្រង់សោយរាជសម្បត្តិបាន ១២ ឆ្នាំ ហើយទ្រង់ព្រះសុវណ្ណគត ក្នុងព្រះជន្មាយុ ៥២ ព្រះវស្សា រវាង គ.ស. ១៥៦៧ ក្រោយដែលបានធ្វើសន្ធិសញ្ញារួចស្រេច ។

# ៨២ - ព្រះសត្ថាទី ១

(គ.ស. ១៥៦៧ - ១៥៧៥ = ៧ឆ្នាំ)

ព្រះសត្ថាទី ១ ជាព្រះរាជបុត្រច្បងរបស់ព្រះបាទបរមិន្ទរាជា ។ ព្រះអង្គឡើងសោយរាជសម្បត្តិនៅពេលដែលព្រះអង្គមានព្រះជន្ម ២៥ ព្រះវស្សាគឺក្នុង គ.ស. ១៥៦៧ ។ ព្រះអង្គទ្រង់តាំងព្រះអនុជរបស់ព្រះអង្គ ទ្រង់ព្រះនាមស្រីសុរិយោពណ៌ ដែលមានព្រះជន្ម ១៩ វស្សា ជាព្រះមហាឧបរាជ ។

ពេលនោះប្រទេសភូមាលើកទ័ពមកច្បាំងនឹងប្រទេសសៀម ។ ព្រះចៅប្រទេសសៀមបានសុំកងទ័ពប្រទេសខ្មែរអោយទៅជួយ ។ ព្រះអង្គទ្រង់ចាត់ព្រះស្រីសុរិយោពណ៌ ជាព្រះមហាឧបរាជអោយលើកទ័ពទៅជួយសៀម, លុះច្បាំងឈ្នះភូមាហើយ ព្រះចៅប្រទេសសៀមពុំយល់នូវមហាគុណដ៏ធ្ងន់នេះទេ បែរជាមើលងាយព្រះស្រីសុរិយោពណ៌ ដូចជាស្ដេចចំណុះទៅវិញ ។ ព្រះចៅប្រទេសកម្ពុជា និង ព្រះមហាឧបរាជទ្រង់ព្រះពិរោធយ៉ាងខ្លាំងចំពោះការនេះ ។

មិនយូរប៉ុន្មាន ប្រទេសភូមាបានលើកកងទ័ពមកធ្វើចម្បាំងនឹងប្រទេសសៀមម្ដងទៀត ។ បានឱកាសល្អដូ-

ធ្មោះ ព្រះសត្ថាទី ១ ក៏ទ្រង់លើកទ័ពទៅវាយដណ្តើមយកអាណាខេត្តសៀមផ្នែកខាងកើតហើយកៀរគ្រួសារខ្មែរបានមកវិញជាច្រើន ។

ព្រះសត្ថាទី ១ ទ្រង់សោយរាជ្យបាន ៨ ឆ្នាំ ។ ព្រះអង្គទ្រង់បង្វែររាជសម្បត្តិថ្វាយមកព្រះរាជបុត្រច្បងរបស់ព្រះអង្គ ទ្រង់ព្រះនាម ព្រះបាទជ័យជេដ្ឋា ។ ព្រះអង្គទ្រង់តាំងព្រះរាជបុត្របន្ទាប់ ព្រះនាមចៅពញាតន់ជាឧបរាជ តាំងព្រះស្រីសុរិយោពណ៌ ជាព្រះអនុជរបស់ព្រះអង្គជាឧបរាជ ។

# ៤៣- ព្រះបាទជ័យជេដ្ឋាទី ១

## [ព្រះជ័យជេស្តា]

(គ.ស. ១៥៧៥ - ១៥៩៣ =លង្វែក)

ព្រះបាទជ័យជេដ្ឋាទី ១ ជាព្រះរាជបុត្រច្បងរបស់ព្រះសត្ថាទី ១ ។ ព្រះអង្គទ្រង់ឡើងសោយរាជសម្បត្តិជំនួសព្រះវររបិតាដែលទ្រង់នៀយណាយព្រះទ័យក្នុងរាជ្យក្នុង គ.ស. ១៥៧៥ គឺក្នុងពេលដែលព្រះអង្គទើបតែនឹងមានព្រះជន្ម ១០ ព្រះវស្សាប៉ុណ្ណោះ ។

ប្រជារាស្ត្រ និង នាម៉ឺនសព្វមុខមន្ត្រី មានសេចក្តី

អាក់អន់ចិត្តជាខ្លាំងចំពោះការដែលព្រះអង្គនៅក្មេងយ៉ាងនេះ ។ សម័យនោះ ប្រទេសកម្ពុជាមានកើតអសន្តិសុខ។ សៀមឃើញដូច្នេះ ក៏លើកកងទ័ពមកវាយក្រុងលង្វែក ប៉ុន្តែត្រូវបាក់ទ័ពបរាជ័យត្រឡប់ទៅស្រុកវាវិញ ។

លុះមកដល់ គ.ស. ១៥៩៣ ក្នុងពេលដែលព្រះបាទជ័យជេដ្ឋាទី ១ មានព្រះជន្មបាន ២៨ ព្រះវស្សានោះ សៀមបានលើកកងទ័ពតាមជើងគោកផង តាមជើងទឹកផង មកច្បាំងនឹងប្រទេសកម្ពុជាយើងទៀត ។ ព្រះអង្គក៏ទ្រង់មានព្រះបញ្ជាអោយត្រៀមកងទ័ពចាំប្រយុទ្ធគ្រប់ទីកន្លែង ។ កងទ័ពសៀមបានវាយធ្លាយខែត្របាត់ដំបង ពោធិ៍សាត់រហូតមកដល់បរិបូរ ហើយក៏លោមព័ទ្ធចាប់ព្រះស្រីសុរិយោពណ៌ប៉ុន្តែព្រះស្រីសុរិយោពណ៌ទ្រង់ភៀសព្រះអង្គមកឯទីក្រុងលង្វែករួច ។ ឯព្រះសត្ថា និង ព្រះបាទជ័យជេដ្ឋា ក៏ទ្រង់ភៀសព្រះអង្គយាងទៅគង់ឯស្ទឹងត្រែង ហើយក៏សុគតនៅទីនោះ ក្នុង គ.ស. ១៥៩៤ ។

កងទ័ពសៀមបានវាយបែកទីក្រុងលង្វែកក្នុង គ.ស. ១៥៩៣ នោះ ។ វាបានចាប់ព្រះស្រីសុរិយោពណ៌ និងរាជវង្សានុវង្សព្រមដោយមនុស្សពេញការចំនួន ៩ ម៉ឺននាក់ យកទៅស្រុកវាទៀតផង ។ វាបានដុតបំផ្លាញផ្ទះ និង ទ្រព្យសម្បត្តិអ្នកស្រុកអស់ជាច្រើន ។ សម័យនោះហើយ ដែលប្រទេសកម្ពុជាត្រូវជួបប្រទះនឹងវិបត្តិដ៏ធំ ។

# ៨៨- ព្រះបាទរាមាជើងព្រៃ

(គ.ស. ១៥៩៤ - ១៥៩៦ = លង្វែក)

កាលដែលកងទ័ពសៀមវាយទីក្រុងលង្វែកបែកហើយមានជ័យជំនះលើប្រទេសកម្ពុជានោះ វាក៏តាំងទ័ពឲ្យនៅត្រួតត្រាប្រទេសកម្ពុជាតមក ។

ពេលនោះព្រះវង្សរាមាជើងព្រៃ បានភៀសខ្លួនចេញពីទីក្រុងលង្វែកទៅគង់នៅក្នុងព្រៃ។ មួយឆ្នាំក្រោយមកគឺក្នុង គ.ស. ១៥៩៤ ព្រះអង្គក៏ទ្រង់កេណ្ឌទ័ពបាន ហើយ ទ្រង់លើកមកច្បាំងកំចាត់ពួកសៀម ទាល់តែបានជ័យជំនះ ហើយព្រះអង្គក៏ទ្រង់ឡើងសោយរាជសម្បត្តិក្នុងឆ្នាំនោះ ។

ក្រោយមក មានជាតិពរទុគ្គេសម្នាក់ឈ្មោះ ឌីអីគ្គោបែលូសូ **(Diego Belloso)** និង ជាតិអេស្ប៉ាញ៉ុលម្នាក់ឈ្មោះ ប្លាស្ស៊ីស **(Blas Ruis)** បានលើកកងទ័ពចេញចេញពីប្រទេសហ្វីលីពីន មកច្បាំងនឹងព្រះអង្គ ។ ជនបរទេសទាំងពីរនាក់ បានធ្វើគតព្រះបាទរាមាជើងព្រៃក្នុង គ.ស. ១៥៩៦ ហើយក៏លើករាជសម្បត្តិថ្វាយព្រះចៅពញាតន់ ដែលត្រូវជាព្រះរាជបុត្ររបស់ព្រះសត្ថាទី១ ។

# ៨៥- ព្រះបរមរាជាទី ១ ឬ [ព្រះពញាតន់]

(គ.ស. ១៥៩៤ - ១៥៩៧ = ៣ឆ្នាំ)

ព្រះបរមរាជាទី ១ ទ្រង់ឡើងសោយរាជសម្បត្តិក្នុង គ.ស. ១៥៩៦ នៅពេលដែលព្រះអង្គមានព្រះជន្ម ១៨-ព្រះវស្សា ។ ព្រះអង្គត្រូវជាព្រះរាជបុត្រទី ២ របស់ព្រះបាទបរមិន្ទរាជាទី ២ (ព្រះសត្ថាទី ១) ។

ព្រះអង្គទ្រង់តាំងបែល្លូសូ ឲ្យធ្វើស្តេចក្រាញ់នៅខេត្តត្បូងឃ្មុំ តាំងប្លាស-រ៉ូស ឲ្យធ្វើស្តេចត្រាញ់នៅខេត្តត្រាំង ដោយសារសគុណដែលអ្នកទាំងពីរបានធ្វើគត់ព្រះបាទរាមាជើងព្រៃយករាជ្យមកថ្វាយព្រះអង្គ ។ ការតែងតាំងជនបរទេសអោយធ្វើធំដូច្នេះជាហេតុនាំឲ្យមានចលាចលក្នុងស្រុក។ ពួកចាមនៅខេត្តត្បូងឃ្មុំនិងអ្នកស្រុកបះបោរលើកជាទ័ពបង្កសង្គ្រាមឡើង ។

បែល្លូសូ ក៏បរាជ័យចាញ់ពួកបះបោរ ហើយស្លាប់ក្នុងសង្គ្រាមនោះ ។ ចំណែកខាងប្លាស-រ៉ូស ក៏លើកទ័ពទៅជួយតែក៏ចាញ់ហើយស្លាប់ក្នុងសង្គ្រាមនោះទៀត ។

ទីបំផុតព្រះបរមរាជាទី ១ លើកទ័ពចេញទៅតយុទ្ធជាមួយពួកបះបោរនោះ ,ហើយទ្រង់ក៏ក្ស័យព្រះជន្មក្នុងសង្គ្រាមនោះទៅទៀតនៅក្នុង គ.ស. ១៥៩៧ ។

# ៤៦- ព្រះបរមរាជាទី ២ ឬ [ព្រះបាទពញាអាន]

(គ.ស. ១៥៩៧ - ១៥៩៩= ៧ខែ)

ព្រះបាទបរមរាជាទី ២ ជាព្រះរាជបុត្រពៅរបស់ព្រះបាទបរមិន្ទរាជា និង ត្រូវជាព្រះអនុជរបស់ព្រះសត្ថាទី ១ និង ព្រះបាទស្រីសុរិយោពណ៌។ ព្រះអង្គទ្រង់ឡើងសោយរាជសម្បត្តិជាតំណពីព្រះបាទបរមរាជាទី ១ ដែលត្រូវជាព្រះភគិនិយោរបស់ព្រះអង្គក្នុងពេលដែលព្រះអង្គមានព្រះជន្ម ៣៣ គឺក្នុង គ.ស. ១៥៩៧ ។

ព្រះអង្គទ្រង់បង្ក្រាបពួកបះបោរក្នុងប្រទេស ដែលបានធ្វើគតព្រះបរមរាជាទី ១ (ពញាតន់) បានស្ងប់រៀបរយដូចប្រក្រតីឡើងវិញ ។

ក្នុង គ.ស. ១៥៩៩មានពួកបះបោរមួយក្រុមនៅភូមិតាកែវក្រុងភ្នំពេញសព្វថ្ងៃនេះ។ពួកបះបោរមានមេបញ្ជាការម្នាក់តាំងខ្លួនជាស្តេច មានឈ្មោះថា (ស្តេចកែវព្រះភ្លើង) បានបង្កកងទ័ពច្បាំងនឹងព្រះបាទបរមរាជាទី ២ គាប់ជួនជាពេលនោះ ព្រះអង្គបានលួចស្រឡាញ់ស្រីម្នាក់ឈ្មោះនាងទាវ ជាប្រពន្ធរបស់ពញាចឹនៅស្រុកស្រីសន្ធរ។ ពញាចឹបានដឹងនូវហេតុការណ៍នោះក៏ចងអាឃាដនឹងព្រះ

អង្គ ហើយបាននាំបក្សពួក រត់ចូលដៃជាមួយស្តេចកែវព្រះភ្លើងធ្វើចម្បាំងជាមួយនឹងព្រះបរមរាជាទី ២ ។

ព្រះបរមរាជាទី ២ ទ្រង់បរាជ័យស្តេចកែវព្រះភ្លើង ហើយទ្រង់ក្ស័យព្រះជន្មក្នុងសង្គ្រាមនោះនៅក្នុង គ.ស.-១៥៩៩ ។

## ៤៧-ព្រះបាទពញាយម(រាជានុសិទ្ធិ)

(គ.ស. ១៥៩៩ - ១៦០០ =ស្រីសន្ធរ)

ព្រះពញាយម រាជានុសិទ្ធិ ជាព្រះរាជបុត្រទី ៣ នៃព្រះសត្ថាមានមាតាជាជាតិលាវ។ ព្រះអង្គបានឡើងសោយរាជ្យតពីព្រះពញាអាន ក្នុង គ.ស. ១៥៩៩ ព្រះជន្ម ១៥ ព្រះវស្សា ។ ពេលដែលព្រះពញាអាន ទ្រង់សុគតទៅនោះ ពួកបះបោរនៅតែមាននៅឡើយ។ ព្រះពញាយមក៏លើកទ័ពទៅបង្ក្រាបពួកបះបោរទាំងនោះ ត្រាតែសុខសាន្តត្រាណហើយ,ព្រះអង្គគិតតែពីអំពើសប្បាយគ្រប់យ៉ាង នាំឲ្យនាម៉ឺនសព្វមុខមន្ត្រីក្នុងប្រទេសអស់សង្ឃឹម ក៏ទៅអញ្ជើញយាងព្រះស្រីសុរិយោពណ៌ ដែលគង់នៅប្រទេសសៀម ឲ្យទ្រង់យាងមកគ្រប់គ្រងរាជសម្បត្តិវិញ ។

ព្រះពញាយម បានភៀសព្រះអង្គទៅចំបះចំបោររាស្ត្រឲ្យបង្កើតចលាចលក្នុងព្រះនគរ តស៊ូជាមួយព្រះស្រីសុរិយោពណ៌ ដរាបដល់ក្ស័យព្រះជន្មក្នុងសង្គ្រាមនោះទៅ។

# ៤៨-ព្រះបាទស្រីសុរិយោពណ៌

(គ.ស. ១៦០០ - ១៦១៨=លង្វែក)

ព្រះបាទស្រីសុរិយោពណ៌ ជាព្រះរាជបុត្រទី ២ របស់ព្រះបាទបរមិន្ទរាជា គឺត្រូវជាព្រះអនុជរបស់ព្រះសត្ថាទី១

កាលដែលទ័ពសៀមវាយបន្ទាយលង្វែកបែក , ពួកវាបានអញ្ជើញព្រះអង្គឲ្យទៅគង់នៅឯស្រុកវា ។ ព្រះអង្គទ្រង់គង់នៅស្រុកសៀមអស់ ៤រាជ្យ ទើបពួកនាម៉ឺនសព្វមុខមន្ត្រីខ្មែរនាំគ្នាទៅអញ្ជើញព្រះអង្គ ឲ្យយាងត្រឡប់មកសោយរាជ្យវិញនៅក្នុង គ.ស. ១៦០០ ។ពេលនោះព្រះអង្គមានព្រះជន្ម ៤៦ ព្រះវស្សា ។

នៅពេលដែលព្រះអង្គបានសោយរាជ្យថ្មី ៗ នោះប្រទេសកម្ពុជាមានកើតចលាចលក្នុងប្រទេសជាខ្លាំង ដោយសារពួកស្ដេចកែវព្រះភ្លើង ដែលធ្វើគត់ព្រះបាទបរមរាជាទី ២ (ពញាអាន) និង ព្រះបាទពញាយមជាមេនាំបះបោរ ។ ប៉ុន្តែព្រះបាទស្រីសុរិយោពណ៌ទ្រង់បានបង្ក្រាបឲ្យរាបទៅវិញ ។

ដោយសារមានការចលាចលក្នុងប្រទេសដូច្នេះ សៀមក៏ឆ្លៀតយកឱកាសនេះ លើកទ័ពចូលមករុករានប្រទេសកម្ពុជាទៀត ។ ប៉ុន្តែព្រះបាទស្រីសុរិយោពណ៌ ទ្រង់ច្បាំងតយុទ្ធទាល់តែបានជ័យជំនះ ហើយកងទ័ពសៀមក៏បាក់ទ័ព

រត់ទៅវិញអស់ទៅ ។

ព្រះបាទស្រីសុរិយោពណ៌ ទ្រង់សោយរាជសម្បត្តិបាន តែ ១៨ ឆ្នាំប៉ុណ្ណោះ ក៏ទ្រង់នឿយណាយព្រះទ័យហើយ ព្រះអង្គទ្រង់ដាក់រាជ្យថ្វាយ ព្រះរាជបុត្ររបស់ព្រះអង្គ ទ្រង់ព្រះនាមព្រះបាទជ័យជេដ្ឋាទី២ ក្នុង គ.ស. ១៦១៨.

ព្រះអង្គទ្រង់សុវណ្ណគត ក្នុង ព្រះជន្ម ៦៤ ព្រះវស្សា គឺក្នុង គ.ស. ១៦១៩ ក្រោយពេលដែលព្រះអង្គដាក់រាជ្យ ១ ឆ្នាំ ។

## ៤៩- ព្រះបាទជ័យជេដ្ឋាទី ២

(គ.ស. ១៦១៨ - ១៦២៨=លង្វាឯម-ឧត្តុង្គ)

ព្រះស្រីសុរិយោពណ៌ទ្រង់សោយរាជ្យសម្បត្តិបាន ១៨ ឆ្នាំ ព្រះអង្គក៏កើតព្រះទ័យនឿយណាយឡើង ។

ទ្រង់ដាក់រាជ្យថ្វាយព្រះរាជបុត្ររបស់ព្រះអង្គ ព្រះនាម ព្រះបាទជ័យជេដ្ឋាទី ២ ក្នុង គ.ស. ១៦១៨ ហើយ តែងតាំងព្រះរាជបុត្រពៅព្រះនាមព្រះឧទ័យជាព្រះអនុជ ព្រះបាទជ័យជេដ្ឋាទី ២ អោយធ្វើជាមហាឧបរាជ ។

ព្រះបាទជ័យជេដ្ឋាទី ២ ទ្រង់សោយរាជ្យបាន ២-ឆ្នាំ ក៏ទ្រង់ផ្លាស់រាជធានីពីលង្វាឯម ទៅតាំងនៅឧត្តុង្គ-

មានជ័យវិញ ក្នុង គ.ស. ១៦២០ ។ ក្នុងឆ្នាំនោះ ព្រះចៅប្រទេសអណ្ណាមបានលើកព្រះរាជបុត្រីមួយព្រះអង្គ ទ្រទ្រង់នូវរូបឆោមស្រស់ប្រិមប្រិយយកមកថ្វាយ ព្រះបាទជ័យជេដ្ឋាទី ២ ។ព្រះអង្គទ្រង់ទទួលយកធ្វើជាព្រះមហេសី ។ លុះចូលមកដល់ គ.ស. ១៦២៣ សៀមបានលើកទ័ពមកច្បាំងពីរលើក ប៉ុន្តែចាញ់ខ្មែរដែរ ។ នៅក្នុងឆ្នាំជាមួយគ្នានេះ ព្រះចៅប្រទេសអណ្ណាមបានផ្ញើព្រះរាជសារមកថ្វាយ ព្រះបាទជ័យជេដ្ឋាទី ២ សុំអនុញ្ញាតអោយយួនចូលមកតាំងទីលំនៅ នៅរកស៊ីក្នុងភូមិភាគខាងត្បូងនៃប្រទេសកម្ពុជា គឺដែនកូសាំងស៊ីនសព្វថ្ងៃនេះព្រមទាំងសុំឲ្យរួចពីមុខពន្ធដារអាករទៀតផង ។ ដោយសារព្រះអង្គសព្វព្រះរាជហឫទ័យនឹងមហេសីយួនពេក ព្រះអង្គក៏ទ្រង់យល់ព្រម ។ ពួកយួនក៏បានមកតាំងទីលំនៅប្រកបរបររកស៊ី នៅដែនកូសាំងស៊ីនតាំងពីពេលនោះមក ។

ព្រះបាទជ័យជេដ្ឋាទី ២ ទ្រង់ព្រះសុវណ្ណគតក្នុង ព្រះជន្ម ៥២ ព្រះវស្សា គឺ ក្នុង គ.ស. ១៦២៨ ។

# ៥០-ព្រះបាទធម្មរាជសំភារ

## (ព្រះពញាតូ)

(គ.ស. ១៦២៩ - ១៦៣៤=កោះឃ្លោក)

ព្រះពញាតូ ជាព្រះរាជបុត្រនៃព្រះបាទជ័យជេដ្ឋាទី២, កាលនៅពីកុមារ ព្រះអង្គត្រូវព្រះបិតាផ្សំផ្គុំទុកជាមួយព្រះអង្គម្ចាស់ក្សត្រីបុប្ផាវតី ។ ប៉ុន្តែមុននឹងព្រះវរបិតាទ្រង់សុវណ្ណគតទៅ ព្រះអង្គបានចេញទៅទ្រង់ផ្នួស ដោយពុំទាន់រៀបពិធីអភិសេក ។ចំណែកកិច្ចការផែនដី ព្រះឧបរាជជាព្រះបិតុលាទ្រង់ព្រះនាមព្រះឧទ័យទ្រង់គ្រប់គ្រង ព្រមទាំងលើកព្រះនាងបុប្ផាវតីជាអគ្គមហេសីថែមទៀត ។

ដល់មកឆ្នាំ ១៦២៩ នៃ គ.ស. ព្រះរាជសំភារបានដាក់ព្រះផ្នួសមកទទួលយករាជសម្បត្តិ ពីព្រះឧទ័យវិញ ។ ព្រះអង្គផ្លាស់រាជធានីទៅគង់នៅឯកោះឃ្លោក ខ្សាច់កណ្តាលសព្វថ្ងៃ ។ ១ ឆ្នាំក្រោយមក ទ្រង់លើកទ័ពទៅវាយខែត្រនគររាជអំពីសៀម ប៉ុន្តែមិនបាន ទ្រង់ក៏កៀរយកគ្រួសារខ្មែរ ឲ្យមកនៅក្នុងខេត្តសៀមរាបជាច្រើនពាន់នាក់ ។ ព្រះរាជសំភារមិនដាច់ព្រះទ័យស្នេហាពីព្រះនាងបុប្ផាវតីទេ,ទ្រង់បានលិខិតអក្សរាឆ្លើយឆ្លងអញ្ជើញព្រះអង្គម្ចាស់ក្សត្រីឲ្យយាងទៅជួបឯកោះឃ្លោក។ ជ្រាបហេតុ

ដូច្នេះ ព្រះឧទ័យខ្វាល់ខ្លាំង ទើបលើកទ័ពទៅតាមចាប់។ ព្រះរាជសំភារលើកទ័ពមកតយុទ្ធវិញ ។ប៉ុន្តែព្រះអង្គថយកម្លាំងជាង ទើបទ្រង់ភៀសរត់ចេញទៅ ។ លុះទៅដល់វាលត្នោតក្នុងស្រុកកញ្ជរ ខែត្រក្រចេះ ទ្រង់ក៏ឡើងទៅពួនលើដើមត្នោតមួយដើម ។

ទ័ពព្រះឧទ័យដេញទាន់ ក៏ថ្វាយគ្រាប់មាសធ្លាក់ព្រះអង្គក្ស័យព្រះជន្មទៅ នា គ.ស. ១៦៣៨ ក្នុងព្រះជន្ម ៣០ វស្សា ។ ព្រះរាជសំភារទ្រង់សព្វព្រះទ័យខាងអក្សរសាស្ត្រណាស់ ព្រះអង្គបាននិពន្ធច្បាប់ផ្សេង ៗ មានច្បាប់ព្រះរាជសំភារជាដើម ទុកទូន្មានកូនចៅជាន់ក្រោយរហូតដល់សព្វថ្ងៃ ។

# ៥១-ព្រះបាទអង្គនន់ទី ១(ព្រះពញាន្ន)

(គ.ស. ១៦៣៨ - ១៦៤០=ឧដុង្គ)

កាលបើព្រះឧទ័យជាព្រះបិតុលាធ្វើគតព្រះរាជសំភារហើយ ព្រះអង្គទងជាព្រះរាជបុត្រ ព្រះបាទជ័យជេដ្ឋាទី ២ និង ជាព្រះអនុជនៃព្រះរាជសំភារ ក៏បានឡើងសោយរាជសម្បត្តិតមក ក្នុងព្រះជន្ម ២៣ វស្សា គ.ស.-១៦៣៨ ។ ក្នុងរាជ្ជកាលព្រះអង្គគ្មានពត៌មានអ្វីសំខាន់

ទេ  មានតែការបះបោរនៃជនមួយពួកនៅស្រុករលាំង-ទ្រាល  ដែលមានជនជាតិតណ្ឌៀជាមេបញ្ជាការ ។ ប៉ុន្តែព្រះអង្គយាងទៅបង្ក្រាបបាន ព្រមទាំងចាប់មេបះ-បោរនោះប្រហារជីវិតចោលទៅ ។

ព្រះអង្គទង  ទ្រង់សុវណ្ណគត នៅខែមិថុនា ១៦៤០ ក្រោយដែលគ្រងរាជសម្បត្តិបាន ៦ ឆ្នាំ ។

## ៥២-ព្រះបទុមរាជាទី ១ ឬ ព្រះបាទអង្គនន់

(១៦៤០ - ១៦៤២ = ឧដុង្គ)

ព្រះបាទអង្គនន់ជាព្រះរាជបុត្រច្បងរបស់ព្រះឧទ័យ ។ ទ្រង់បានសោយរាជ្យក្នុង គ.ស. ១៦៤០ នៅរាជធានី - ឧដុង្គមានជ័យ ។

កាលបើរាជសម្បត្តិបានមកព្រះបាទអង្គនន់ទី១ ដូច្នេះ ព្រះអង្គចន្ទព្រះអនុជនៃព្រះរាជសំភារក៏អាក់អន់ព្រះទ័យ នាំបំបះពួកចាមជ្វាធ្វើគតព្រះអង្គនន់ និងព្រះឧទ័យក្ស័យ ព្រះជន្មទៅក្នុង គ.ស. ១៦៤២ ។

កាលនោះព្រះរាជបុត្របីព្រះអង្គនៃព្រះឧទ័យបានរត់-

រួច គឺព្រះអង្គអីមបានរត់ទៅជ្រកជាមួយព្រះមាតាព្រះបាទអង្គចន្ទ ។ ឯព្រះរាជបុត្រទី ២ គឺព្រះពញាសូរ និង-ព្រះអង្គតន់ យាងដោះព្រះអង្គទៅពួននៅជាមួយព្រះមហេសីឃួន នៃសពព្រះជ័យជេដ្ឋាទី ២ ។ ដូច្នេះនគរក៏កើតចលាចលវឹកវរជាខ្លាំង ប្រជារាស្ត្រពុំបានសុខសប្បាយឡើយ ។

## ៥៣-ព្រះបាទបទុមរាជាទី ២ ឬ ព្រះបាទរាមាធិបតីច័ន្ទ

(គ.ស. ១៦៤២ - ១៦៥៨ =ខុង្គ)

ព្រះបាទរាមាធិបតីចន្ទ ជាព្រះអនុជនៃព្រះរាជសំភារមានព្រះមាតាជាលាវ ។ ក្នុង គ.ស. ១៦៤២ ដែលព្រះអង្គនាំពួកចាមជ្វាបះធ្វើគតព្រះអង្គនន់បាន ព្រះអង្គក៏ឡើងសោយរាជ្យតមក ដោយយកស្រីជ្វាជា អគ្គមហេសី ហើយចូលសាសនាមហាម៉ាត់ផង ។ដូច្នេះបានជាគេហៅថាព្រះអង្គចន្ទមហាម៉ាត់ ឬ អ៊ីប្រាហ៊ីម ។ ទ្រង់តាំងព្រះអង្គអីមព្រះរាជបុត្រព្រះឧទ័យដែលទៅជ្រកជាមួយ ព្រះមាតារបស់ព្រះអង្គជាព្រះកែវហ្វា ហើយតាំងចាមជ្វាជា

នាម៉ឺនធំ ៗ ក្នុងព្រះនគរ ជាហេតុនាំឲ្យប្រជាជនខ្មែរកើតក្តីក្តៅក្រហាយជាខ្លាំង ។

ដល់មក គ.ស. ១៦៥៨ ព្រះពញាសូរ និងព្រះអង្គតន់ដែលរត់ទៅគង់នៅជាមួយព្រះមហេសីយួន នៃសព-ព្រះជ័យជេដ្ឋានោះ បានទៅពឹងយួនឲ្យលើកទ័ពមកវាយនគរកម្ពុជា ចាប់យកព្រះបាទរាមាធិបតីចន្ទ ទៅឃុំទុកនៅស្រុកយួន ។ មួយឆ្នាំកន្លងមក គឺនៅក្នុង គ.ស. ១៦៥៩ ព្រះបាទរាមាធិបតីចន្ទ ក៏ទ្រង់សុវណ្ណគតក្នុងស្រុកយួននោះទៅ ក្នុងព្រះជន្ម ៤០ វស្សា ។

## ៥៤-ព្រះបាទបទុមរាជាទី ៣ ឬ ព្រះពញាសូរ

(១៦៥៨ - ១៦៧២ =ខុង្គ)

ព្រះបាទបទុមរាជាទី ៣ ជាព្រះរាជបុត្រច្បងរបស់ព្រះឧទ័យ លុះព្រះអង្គបានពឹងយួនឲ្យលើកទ័ព មកវាយប្រទេសកម្ពុជា ចាប់យកព្រះរាមាធិបតីចន្ទទៅឃុំនៅក្នុងស្រុកយួនរួច ទ្រង់ក៏ឡើងគ្រងរាជសម្បត្តិតរៀងមក ។ កាលដែលរជ្ជកាលរបស់ព្រះអង្គមានការបះបោរពួកចាមជ្វា

នៅខេត្តត្បូងឃ្មុំ ទ្រង់ក៏លើកទ័ពទៅវាយខ្ចាត់ខ្ចាយអស់។ មេបះបោររត់ទៅខេត្តសៀមរាប រួចឆ្លងចូលទៅប្រទេសសៀម ព្រមទាំងព្រះរាជបុត្របីព្រះអង្គរបស់ព្រះរាមាធិបតីចន្ទ និង បក្សពួកទៀតចំនួន ២២២៤នាក់ផង ។ លុះប្រទេសកម្ពុជាបានស្ងប់ស្ងាត់ហើយ ដល់មក គ.ស. - ១៦៧២ ព្រះបាទជ័យជេដ្ឋាទី ៣ ជាព្រះសុណិសា (១) របស់ព្រះអង្គបានធ្វើគតព្រះអង្គយករាជសម្បត្តិ ។ ប៉ុន្តែមួយឆ្នាំក្រោយមក ( គ.ស. ១៦៧៣ ) ព្រះអគ្គមហេសីនៃព្រះបទុមរាជា ក៏ញុះញង់ពួកចាមជ្វាអោយធ្វើគតព្រះជ័យជេដ្ឋាទី ៣ បានវិញ ។

## ៥៥- ព្រះបាទអង្គជ័យ

(គ.ស. ១៦៧៣ - ១៦៧៥=២ដុង្គ)

ក្រោយដែលព្រះមហេសីនៃព្រះបទុមរាជា បញ្ចុះបញ្ចូលឲ្យពួកចាមជ្វា បះបោរធ្វើគតព្រះជ័យជេដ្ឋាទី ៣ បានហើយ ក្រុមព្រះរាជវង្សានុវង្ស ក៏ព្រមព្រៀងលើករាជសម្បត្តិថ្វាយទៅព្រះបាទអង្គជ័យ ជាព្រះរៀមនៃព្រះ

---

១- ព្រះសុណិសា = កូនប្រសារ ។

បាទជ័យជេដ្ឋាទី ៣ ជាព្រះរាជនត្តានៃព្រះឧទ័យ និង ជាព្រះរាជបុត្រនៃព្រះបទុមរាជាទី ៣ ( ព្រះពញាសូរ ) ក្នុង គ.ស. ១៦៧៣ ។ ព្រះបាទអង្គជ័យឡើងគ្រងរាជ្យបានតែជាង ១ ឆ្នាំ គឺរវាង គ.ស. ១៦៧៥ ព្រះអង្គនន់ទី ២ និង ព្រះអង្គតន់ជាព្រះអនុជ បានលើកទ័ពមក-ច្បាំងដោយមានយួនជាជំនួយផង ។ ព្រះបាទអង្គជ័យក៏សុវណ្ណគតក្នុងពេលនោះទៅ ។

## ៥៦- ព្រះបាទជ័យជេដ្ឋាទី ៤

(គ.ស. ១៦៧៥ - ១៧០៦= ឧដុង្គ)

ព្រះមហាក្សត្រអង្គនេះជាព្រះរាជបុត្ររបស់ព្រះបាទ-បទុមរាជា។ ព្រះអង្គទ្រង់វាយកំចាត់ព្រះបាទអង្គនន់ទី ២ ចេញហើយ ទ្រង់ឡើងសោយរាជសម្បត្តិនៅរាជធានីឧដុង្គមានជ័យ ក្នុង គ.ស. ១៦៧៥ ។

ដូច្នេះ ព្រះបាទអង្គនន់ទី ២ ក៏រត់ទៅគង់នៅឯព្រៃនគរ ហើយយកយួនធ្វើជាមិត្រ ។ ដោយចង់ដណ្តើមអំណាចព្រះអង្គនន់ទី ២ បានលើកកងទ័ពមានយួនផង-ចិនផង មកច្បាំងនឹងព្រះជ័យជេដ្ឋាទី ៤ ជាញឹកញយបន្តែចាញ់រាល់លើក ។ ទីបំផុតព្រះបាទអង្គនន់ទី ២ ក៏

ទ្រង់សុំសារភាពចុះចូលក្នុង គ.ស. ១៦៧១ ។ ព្រះបាទ-ជ័យជេដ្ឋាទី ៤ ក៏ទ្រង់យល់ព្រមហើយប្រទានអោយព្រះបាទអង្គនន់ទី ២ គង់នៅស្រុកស្រីសន្ធរ ។ ប្រទេស-កម្ពុជាក៏បានសេចក្ដីសុខសាន្តត្រាណរហូតមក ។ លុះក្រោយមក , ព្រះបាទអង្គនន់ទី ២ ក៏ទ្រង់សុគតនៅស្រុកស្រីសន្ធរនោះ ។

ប៉ុន្តែក្នុង គ.ស. ១៦៩៩ មាននាម៉ឺនក្បត់ម្នាក់ឈ្មោះឧកញ៉ានរិន្ទអឹម បានទៅពឹងពាក់លើកម្លាំងទ័ពយួនអោយមកជួយច្បាំងដណ្ដើមរាជ្យពីព្រះបាទជ័យជេដ្ឋាទី ៤ ប៉ុន្តែកងទ័ពខ្មែរដេញខ្ចាត់ខ្ចាយទៅវិញអស់ ។

នៅក្នុងរាជ្យរបស់ព្រះអង្គជាង ៣១ ឆ្នាំនេះ ព្រះបាទជ័យជេដ្ឋាទី ៤ ទ្រង់ដាក់រាជ្យថ្វាយព្រះបាទធម្មរាជា ជាព្រះរាជបុត្ររបស់ព្រះអង្គ ២ ឆ្នាំ គឺពី គ.ស. ១៧០២ - ដល់ ១៧០៤ ។

លុះដល់ គ.ស. ១៧០៦ ព្រះបាទជ័យជេដ្ឋាទី ៤ ក៏ទ្រង់ដាក់រាជ្យព្រះបាទធម្មរាជារហូតមក ។

# ៥៧- ព្រះបាទអង្គអឹម

(រាជ្យលើកទី១, ពី១៧០០-១៧០១ = ពោធិសាត់)

ដោយទ្រង់នឿយណាយនឹងរាជសម្បត្តិ ព្រះបាទជ័យជេដ្ឋាទី ៤ ក៏បង្វែររាជ្យថ្វាយ មកព្រះភគិនិយោជដួនមួយព្រះអង្គ ព្រះនាមព្រះអង្គអឹម ជាព្រះរាជបុត្រនៃ-ព្រះអង្គនន់ទី ២ មាតាជានារីចិន ហើយដែលទ្រង់បានតាំងជាព្រះកែវហ្វា ។

ព្រះអង្គអឹមឡើងសោយរាជសម្បត្តិ ក្នុង គ.ស.-១៧០០ ប៉ុន្តែដល់ គ.ស. ១៧០១ ព្រះអង្គក៏បង្វែររាជ្យថ្វាយទៅ ព្រះជ័យជេដ្ឋាទី ៤ វិញ ។

ឯព្រះជ័យជេដ្ឋាទី ៤ ក៏មកទទួលរាជសម្បត្តិវិញរហូតដល់ គ.ស. ១៧០៦ ។

# ៥៨- ព្រះបាទធម្មរាជាទី ២

(រាជ្យលើកទី១, គ.ស. ១៧០២ - ១៧០៤)

ព្រះបាទធម្មរាជាទី ២ ជាព្រះរាជបុត្ររបស់ព្រះបាទជ័យជេដ្ឋាទី ៤ ។

ក្រោយពេលដែលព្រះបាទអង្គអឹម ថ្វាយរាជសម្បត្តិមកព្រះអង្គវិញនោះ , ព្រះបាទជ័យជេដ្ឋាទី ៤ ក៏លើករាជសម្បត្តិថ្វាយ ព្រះបាទធម្មរាជាទី ២ ដែលជាព្រះរាជបុត្ររបស់ព្រះអង្គទៀត ។

ក្នុង គ.ស. ១៧០២ គឺនៅពេលដែលព្រះអង្គឡើងសោយរាជសម្បត្តិនោះ ព្រះធម្មរាជាទី ២ ទើបតែមានព្រះជន្ម ១២ ព្រះវស្សាប៉ុណ្ណោះ ។

ដោយសារព្រះអង្គនៅក្មេងពេកដូច្នេះ ព្រះបាទធម្មរាជាទី ២ ទ្រង់សោយរាជសម្បត្តិបានតែ ២ ឆ្នាំ ក៏ទ្រង់ថ្វាយរាជ្យទៅព្រះបិតាវិញ ក្នុង គ.ស. ១៧០៤ ។

# ៥៩ - ព្រះបាទធម្មរាជាទី ២

(រាជ្យលើកទី២, ១៧០៦ - ១៧១០= ឧដុង្គ)

ព្រះបាទធម្មរាជាទី ២ ជាព្រះរាជបុត្រនៃព្រះបាទ-ជ័យជេដ្ឋាទី ៤ ។ ទ្រង់បានទទួលរាជសម្បត្តិពីព្រះវរបិតាក្នុង គ.ស. ១៧០២ ដល់ ១៧០៤ ម្តង តែព្រះអង្គនៅក្មេងពេក ក៏បង្វែររាជ្យថ្វាយទៅព្រះបិតាវិញ ។ លុះមកដល់ គ.ស. ១៧០៦ ព្រះអង្គឡើងគ្រងរាជ្យម្តងទៀត ។ នៅដើមរាជ្យព្រះអង្គ មានលាវ ១ ក្រុមដែលនៅក្នុងភូមិ ((បារាយណ៍ក្បត់ជុំ)) នាំគ្នាបះបោរឡើង។ ព្រះអង្គចាត់ទ័ពឲ្យទៅវាយខ្ចាត់ខ្ចាយអស់ ខ្លះរត់ចូលព្រៃ ខ្លះរត់ទៅជ្រកនៅនឹងព្រះកែវហ្វាអង្គអឹម ។ ពេលនោះព្រះអង្គអឹមបានឱកាសល្អ ក៏បញ្ជាមេកងលាវទៅកេណ្ឌទ័ពពីខាងត្បូង បានយួនប្រហែល ២០.០០០ នាក់រួម-ជាមួយនឹងទ័ពលាវ លើកទៅព័ទ្ធក្រុងឧដុង្គ ឡោមចាប់ព្រះធម្មរាជា ។ ព្រះធម្មរាជាអស់សង្ឃឹមទៅហើយ តែទទួលមានយប់មួយនោះ ជាឱកាសល្អទ្រង់ក៏នាំព្រះអនុជ-ព្រះនាមអង្គទង និង ព្រះរាជបុត្រមួយព្រះអង្គភៀសព្រះអង្គយាងទៅគង់នៅប្រទេសសៀម ក្នុងក្រុងស្រីអយុ-ធ្យា នា គ.ស. ១៧១០ ។

ព្រះកែវហ្វាអង្គអឹមក៏ឡើងសោយរាជសម្បត្តិតមក . . ។

# ៦០- ព្រះកែវហ្វាអង្គអឹម

(រាជ្យលើកទី៣, គ.ស. ១៧១០-១៧២២ = ១ដង្គ)

ព្រះអង្គអឹមជាព្រះរាជបុត្រនៃព្រះអង្គនន់ទី ២ ។ព្រះអង្គនាំបក្សពួកមកវាយកំចាត់ព្រះធម្មរាជា , ក៏ភៀសព្រះអង្គទៅស្រុកសៀម ហើយព្រះអង្គក៏ឡើងសោយរាជសម្បត្តិមកនៅក្នុង គ.ស. ១៧០១ . . . ។

នៅដើមរាជ្យព្រះអង្គ ព្រះចៅសៀមបញ្ជូនទូតឲ្យនាំព្រះរាជសំបុត្រអក្សរមកដល់ព្រះអង្គអឹមថា : ((អោយទ្រង់ថ្វាយរាជសម្បត្តិទៅព្រះធម្មរាជាវិញ)) តែព្រះអង្គអឹមមិនព្រម , ស្ដេចសៀមក៏នៅស្ងៀម ។ លុះមកដល់ គ.ស. ១៧១៧ ព្រះរាជាប្រទេសសៀមចាត់កងទ័ពឲ្យមកច្បាំងនឹងព្រះអង្គអឹម យករាជ្យថ្វាយព្រះធម្មរាជា ។ ដោយអានកងទ័ពយួនជួយផង ព្រះអង្គអឹមលើកទ័ពទៅទប់នៅខែត្រពោធិសាត់ ប៉ុន្តែលុះឃើញខាងសៀមខ្លាំងពេក ទ្រង់ក៏សុំឲ្យស្ដេចសៀមដកទ័ពថយទៅវិញ ហើយសន្យាថា ((នឹងដាក់នគរខ្មែរជាចំណុះនគរសៀម មានផ្កាមាសផ្កាប្រាក់ជាសួយនាំទៅថ្វាយ)) ។ កិច្ចនេះបណ្ដាលឲ្យនាម៉ឺន និង រាស្ត្រពុំសប្បាយចិត្តឡើយ ។

ក្រោយមកព្រះអង្គអឹមក៏បង្វែររាជសម្បត្តិ ថ្វាយមកព្រះរាជបុត្រព្រះអង្គព្រះនាមអង្គជ័យ ឬ ព្រះសត្ថាទី ២ ក្នុង គ.ស. ១៧២២ ។

## ៦១- ព្រះសត្ថាទី ២ ឬ ព្រះអង្គជ័យ

(១៧២២ - ១៧៣៨ = ១៦ឆ្នាំ)

ព្រះសត្ថាទី ២ ជាព្រះរាជបុត្រព្រះអង្គអឹម ។ ព្រះអង្គទទួលរាជសម្បត្តិពីព្រះបិតា ពី គ.ស. ១៧២២ ដល់ គ.ស. ១៧២៩ ព្រះអង្គអឹមមកយករាជសម្បត្តិវិញ ។ ដោយបណ្ដាជនពុំសូវសប្បាយចិត្ត ព្រះអង្គអឹមសោយរាជ្យបានតែ ៧ ខែ ក៏បង្វែររាជ្យថ្វាយមកព្រះសត្ថាវិញដដែល ហើយទ្រង់យកទីជាព្រះឧបយោរាជរហូតមក ។ នៅ គ.ស. ១៧៣១ ក្នុងរាជ្យព្រះសត្ថាទី ២ មានលាវម្នាក់នៅភូមិប្រសូត្រ, ខេត្រស្វាយរៀងបញ្ចុះបញ្ចូលរាស្ត្រលើកគ្នាទៅកាប់សម្លាប់យួន ។

ព្រះអង្គបានចាត់រាជបរិវារឲ្យទៅឃាត់ ។ ឯយួនបានឱកាសក៏លើកទ័ពមកច្បាំងខ្មែរ, តែចាញ់ដៃរាល់លើកហើយថយទៅនៅក្នុងខេត្តវិញ-ឡុង និង មីរថវិញទៅ. ក្រោយមកព្រះសត្ថាសង្ស័យមហេសី និង ព្រះរាជវង្ស

ទាំងនេះ ផាតង់រួមគំនិតក្បត់ព្រះអង្គ ។ ព្រះមហេសី និង ព្រះរាជវង្ស អន់ព្រះទ័យក៏ទៅកេណ្ឌទ័ពមកច្បាំង នឹងព្រះសត្ថា ។ ព្រះសត្ថាបរាជ័យ ក៏ភៀសព្រះអង្គ ទៅដែនកូសាំងស៊ីនបាត់ទៅ ។ តមកព្រះអហេសី ,ព្រះ រាជវង្ស និង នាម៉ឺន ព្រមព្រៀងគ្នាទៅសុំយាងព្រះធម្ម-រាជាទី ២ ដែលគង់នៅប្រទេសសៀមអោយមក សោយរាជ្យវិញ ។

## ៦២- ព្រះបាទអង្គអឹម

(រាជ្យលើកទី៣,គ.ស. ១៧២៩ = ១ដុង្គ)

ក្រោះព្រះសត្ថាទី ២ (ព្រះអង្គជ័យ) ជាព្រះរាជបុត្រ ទ្រង់ឡើងសោយរាជសម្បត្តិបាន ៧ ឆ្នាំ ព្រះអង្គក៏ទ្រង់ មានព្រះទ័យនឿយណាយនឹងរាជសម្បត្តិ ។ ទ្រង់ក៏លើក រាជ្យថ្វាយមកព្រះបិតា គឺ ព្រះបាទអង្គអឹមវិញ ។

ដូច្នេះព្រះបាទអង្គអឹម ក៏ទ្រង់ឡើងសោយរាជសម្បត្តិ វិញ ក្នុង គ.ស. ១៧២៩ ។

ប៉ុន្តែព្រះអង្គសោយរាជ្យបានតែ ៧ ខែប៉ុណ្ណោះ ព្រះ-អង្គក៏ទ្រង់លើករាជសម្បត្តិ ថ្វាយទៅព្រះរាជបុត្រវិញក្នុង គ.ស. ១៧៣០ ។

# ៦៣- ព្រះសត្ថាទី ២ [ព្រះអង្គជ័យ]

(រាជ្យលើកទី២, គ.ស. ១៧៣០ - ១៧៣៨)

ព្រះសត្ថាទី ២ ទ្រង់ឡើងសោយរាជសម្បត្តិ លើកទី ២ ក្នុង គ.ស. ១៧៣០ នៅរាជធានីឧដុង្គមានជ័យ។

ព្រះអង្គទ្រង់ឡើងសោយរាជសម្បត្តិបាន ១ ឆ្នាំ គឺនៅ គ.ស. ១៧៣០ មានលាវម្នាក់នៅភូមិប្រសូត្រ,ស្រុកបាភ្នំ បានបំបះបំបោរពួករាស្ត្រឲ្យលើកគ្នាទៅកាប់សម្លាប់-យួន ។ យួនឃើញដូច្នេះ ក៏លើកទ័ពមកច្បាំងនឹងប្រទេសកម្ពុជា ។ ប៉ុន្តែទ័ពយួនបរាជ័យ ហើយថយទៅខេត្តវិញ-ឡុង និង មី-ថរ វិញអស់ទៅ ។

លុះមកដល់ គ.ស. ១៧៣៨ ព្រះសត្ថាទ្រង់មានសេចក្ដីសង្ស័យនឹងមហេសីរបស់ព្រះអង្គ ព្រះទាំងព្រះរាជវង្សព្រះឧទ័យថា នឹងរំលំព្រះអង្គចេញពីរាជបល្លង្គ ។ ព្រះ-អង្គទ្រង់រៀបចំគ្រោងការប្រុងនឹងធ្វើគត ព្រះមហេសីនិង ព្រះរាជវង្សព្រះឧទ័យ ។ ប៉ុន្តែព្រះមហេសីរបស់-ព្រះអង្គ និង ព្រះរាជវង្សព្រះឧទ័យជ្រាបការណ៍ ក៏ទៅកេណ្ឌទ័ពលើកមកច្បាំងនឹងព្រះសត្ថាទី ២ ។ ព្រះសត្ថាទី ២ តស៊ូមិនឈ្នះ ព្រះអង្គក៏ទ្រង់ភៀសទៅគង់នៅដែនកូសាំងស៊ីន ។ ព្រះមហេសី (ព្រះអង្គម្ចាស់ក្សត្រីស្រីសុ-ជាតា) របស់ព្រះសត្ថាទី ២ ព្រមដោយព្រះរាជវង្សានុ

វង្ស និង នាម៉ឺនសព្វមុខមន្ត្រីបានមូលមតិគ្នាទៅអញ្ជើញព្រះបាទធម្មរាជាទី ២ ដែលគង់នៅប្រទេសសៀម ឲ្យយាងមកសោយរាជសម្បត្តិវិញក្នុង គ.ស.១៧៣៨ នោះ។

## ៦៨ – ព្រះបាទធម្មរាជាទី ២

(រាជ្យលើកទី៣, ១៧៣៨ – ១៧៤៧ = ឧដុង្គ)

ព្រះបាទធម្មរាជាទី ២ ជាព្រះរាជបុត្រនៃព្រះបាទជ័យជេដ្ឋាទី ៤ ។ ព្រះអង្គបានសោយរាជ្យពី គ.ស. ១៧០២ ដល់ ១៧០៤ម្តង, តែព្រះអង្គនៅក្មេងពេកក៏បង្វែររាជ្យទៅព្រះបិតារបស់ព្រះអង្គវិញ ។ លុះដល់ គ.ស. ១៧០៦ ទ្រង់បានសោយរាជ្យម្តងទៀត តែត្រូវព្រះអង្គអឹមច្បាំងដណ្តើមរាជសម្បត្តិ, ហើយព្រះអង្គក៏ភៀសទៅគង់នៅស្រុកសៀមទៅ ។

ដល់មកក្នុង គ.ស. ១៧៣៨ នេះ ព្រះអង្គត្រូវគេយាងមកសោយរាជ្យម្តងទៀត ជារាជ្យលើកទី៣ ។

ក្នុងរាជ្យព្រះអង្គលើកក្រោយនេះ ពង្សាវតារខ្មែរថែងថា : ប្រទេសកម្ពុជាបានសុខសាន្តត្រាណាហូតដល់ទ្រង់សុវណ្ណគត ។ ព្រះធម្មរាជាទី ២ បានតែងតាំងព្រះអនុជព្រះនាមព្រះអង្គទងជា ព្រះឧបរាជ,តាំងព្រះឧទ័យ

ព្រះរាជបុត្រព្រះអង្គទងជាព្រះឧបរាជ , ឯព្រះអង្គអឹមជាព្រះរាជបុត្ររបស់ព្រះអង្គជា ព្រះកែវហ្វា ។

ព្រះធម្មរាជាទី ២ ទ្រង់ព្រះសុវណ្ណគតក្នុង គ.ស.-១៧៤៧ ក្រោយពេលដែលទ្រង់សោយរាជ្យបាន ៩ឆ្នាំ ។

## ៦៥ - ព្រះបាទធម្មរាជាអង្គអឹម

(១៧៤៧ = ខុជុង្គ)

ព្រះបាទធម្មរាជាអង្គអឹម ជាព្រះរាជបុត្រនៃព្រះធម្ម-រាជាទី ២ ។ ទ្រង់បានសោយរាជ្យតពីព្រះបិតា ក្នុង គ.ស. ១៧៤៧ ។ ព្រះធម្មរាជាអង្គអឹមនេះហើយ ដែលជាបុត្រកំសត់ទៅគង់នៅស្រុកសៀមជាមួយនឹង ព្រះធម្ម-រាជាទី ២ ជាព្រះបិតា កាលដែលព្រះកែវហ្វាអង្គអឹមដណ្តើមយករាជ្យ ។

ព្រះបាទធម្មរាជាអង្គអឹមសោយរាជ្យបានតែរវាង ១-ឆ្នាំ ក៏ត្រូវព្រះអនុជព្រះអង្គ ព្រះនាមព្រះអង្គអ៊ឹងធ្វើគតទៅ ។

ព្រះអង្គអ៊ឹងជាព្រះរាជបុត្រ ព្រះធម្មរាជាទី ២ ដែរតែព្រះមាតាជាជាតិសៀម ។ ក្នុងពេលធ្វើព្រះរាជពិធីសុកាន្ត ព្រះវរបិតាប្រទានព្រះនាមថា ព្រះស្រីសុរិយោ។

# ៦៦ - ព្រះបាទអង្គទងទី ២

(រាជ្យលើកទី១, ១៧៤៧ - ១៧៤៩ = ឧដុង្គ)

ព្រះបាទអង្គទងទី ២ ជាព្រះរាជបុត្របន្ទាប់របស់ព្រះជ័យជេដ្ឋាទី ៤ និង ត្រូវជាព្រះអនុជកំសត់របស់ព្រះបាទធម្មរាជាទី ២ ដោយធ្លាប់ទៅគង់នៅស្រុកសៀមជាមួយគ្នា កាលព្រះកែវហ្វាអង្គអឹមដណ្តើមយករាជ្យ ។

លុះដល់ព្រះអង្គអ៊ឹងធ្វើគត ព្រះធម្មរាជាអង្គអឹមបានហើយ ព្រះអង្គអ៊ឹងក៏ប្រាថ្នានឹងឡើងសោយរាជសម្បត្តិ-តែព្រះរាជវង្សានុវង្ស និង នាម៉ឺនសព្វមុខមន្ត្រីពុំព្រម គេក៏លើករាជ្យថ្វាយមកព្រះអង្គទងទី ២ ព្រះជន្ម ៥៦ ព្រះវស្សាដែលជាអតីតព្រះឧបយោរាជ១០ឆ្នាំរួចមកហើយ។

រាជ្យព្រះអង្គទងទី ២ កន្លងទៅបានពីរឆ្នាំ គឺ នៅ គ.ស. ១៧៤៩ ព្រះសត្ថាទី ២ ដែលរត់ទៅគង់នៅដែន-កូសាំងស៊ីននោះ ក៏នាំទ័ពយួនមកច្បាំងនឹងព្រះអង្គ ។ កាលនោះមានមេទ័ព ២ នាក់ គឺលោកក្រឡាហោមឧកទៅហ្វាយខែត្រពោធិសាត់ និងលោកឧកញ៉ាសួគ៌ាលោកបានបណ្តោះព្រះអង្គទងអោយទៅគង់នៅស្រុកសៀម ,-ហើយមេទ័ពទាំង ២ នោះ ក៏រងសង្គ្រាមឡើង ។

ព្រះសត្ថាទី ២ បរាជ័យហើយសុគតក្នុងសង្គ្រាមនោះទៅ ។ តមក លោកមេទ័ពបានទៅសុំព្រះចៅសៀម-

យកព្រះជ័យជេដ្ឋាទី ៥ (ព្រះអង្គស្ងួន) អោយយាងមក គ្រប់គ្រងរាជសម្បត្តិនៅប្រទេសកម្ពុជាវិញ ។

## ៦៧ -ព្រះបាទជ័យជេដ្ឋាទី ៥

## [ព្រះអង្គស្ងួន]

(គ.ស. ១៧៤៩ - ១៧៥៥ = ខុង្គ)

ព្រះបាទជ័យជេដ្ឋាទី ៥ ជាព្រះរាជបុត្រនៃព្រះធម្មរាជាអង្គអឹម ។ ក្នុងកាលដែលព្រះអង្គឡើងគ្រប់គ្រងរាជសម្បត្តិ ទ្រង់បានតែងតាំងលោកមេទ័ពខ្មែរទាំងពីរដែលមានសគុណលើប្រទេសជាសម្តេចចៅហ្វា។រឿងនេះអស់នាម៉ឺនឯទៀតច្រណែនក៏រកហេតុបង្កុសថាសេម្តចចៅហ្វា ក្បត់ផែនដី ។

ព្រះរាជាជឿនាម៉ឺនទាំងនោះ ក៏អោយគេយកសម្តេចចៅហ្វាទៅធ្វើទោសដល់ជីវិត ។ សម្តេចចៅហ្វាដឹងខ្លួនទាន់ក៏រត់ទៅនៅស្រុកសៀមទៅ ។

ពីរឆ្នាំក្រោយមក គឺក្នុង គ.ស. ១៧៥១ មាននាម៉ឺនខ្មែរម្នាក់ឈ្មោះ (( ក្សត្រឯក )) បានយកមនុស្សម្នាក់ឈ្មោះ (( សួស្តី )) ប្រកាសថាជាអ្នកខ្លាំងពូកែ និង-

មនុស្សខ្ទិនម្នាក់ទៀតថាជាត្រកូលស្តេច ដើរបញ្ចុះបញ្ចូលរាស្ត្រ លើកគ្នាទៅច្បាំងនឹងព្រះមហាក្សត្រ តែត្រូវកងទ័ពហ្លួងដេញវាយខ្ចាត់ខ្ចាយអស់ ហើយចាប់មេបះបោរនោះសម្លាប់ចោលទៅ ។

ព្រះជ័យជេដ្ឋាទី ៤ ទ្រង់សុវណ្ណគតនៅក្នុង គ.ស.-១៧៥៥ ក្រោយពេលដែលសោយរាជសម្បត្តិបាន៧ឆ្នាំ ។

# ៦៨ - ព្រះបាទអង្គទងទី ២

(រាជ្យលើកទី១, គ.ស. ១៧៥៦ - ១៧៥៧ = ឧដុង្គ)

ព្រះអង្គទងទី ២ ជាព្រះរាជបុត្រទី ២ នៃព្រះជ័យ-ជេដ្ឋាទី ៤ ។ លុះព្រះជ័យជេដ្ឋាទី ៤ ទ្រង់សុវណ្ណគតទៅ គេក៏ថ្វាយរាជសម្បត្តិមកព្រះអង្គទងទី ២ វិញក្នុង គ.ស. ១៧៥៦ ។ បន្ទាប់ពីសោយរាជ្យបាន ១ឆ្នាំ ព្រះអង្គក៏យាងចេញពីឧដុង្គទៅគង់នៅខេត្តពោធិសាត់ ។ ដល់ក្រោយមក ទ្រង់ក៏សុគតនៅទីនោះទៅក្នុងព្រះជន្ម-៦៥ វស្សា ក្នុង គ.ស. ១៧៥៧ ។

ក្នុងរជ្ជកាលព្រះអង្គទងលើកក្រោយនេះ មានព្រឹត្តិ-ការណ៍មួយគឺ : ព្រះអង្គអ៊ឹងស្រីសុរិយោ បានប្រើមនុស្សឲ្យទៅធ្វើគត ព្រះឧទ័យអង្គតន់ នៅក្នុងក្រុងឧដុង្គ ។ ព្រះឧទ័យអង្គតន់ ក៏ដោះព្រះអង្គទៅគង់នៅខែត្រពាម

(( ហាទៀង )) ជាមួយនឹងសម្តេចព្រះសុទត្ត ((ជាតិចិននាមម៉ាក់តុង)) ជាព្រះបិតាធម៌ ។ ក្រោយមកព្រះសុទត្តក៏លើកទ័ពមកច្បាំងនឹងព្រះអង្គអ៊ីង ឯក្រុងឧដុង្គវិញ ។ ព្រះសុទត្ត និង ព្រះឧទ័យអង្គតន់ លើកទ័ពពីដែនកូសាំងស៊ីន អកវាយទ័ពព្រះអង្គអ៊ីងខ្ចាត់ខ្ចាយអស់ ព្រមទាំងចាប់ព្រះអង្គអ៊ីង និង ព្រះរាជវង្សធ្វើគតគោលបង់ ។ ពេលនោះមានតែព្រះអង្គនន់ទី ២ ជាព្រះរាជបុត្រព្រះជ័យជេដ្ឋាទី ៥ ទេ ដែលដោះព្រះអង្គទៅដែនសៀមរួចទាន់ ។ តមកព្រះឧទ័យអង្គតន់ក៏ឡើងគ្រប់គ្រងរាជសម្បត្តិ បន្ទាប់ពីព្រះអង្គទងទី ២ ។

# ៦៩- ព្រះបាទឧទ័យរាជា

## [ ព្រះអង្គតន់ ]

(គ.ស. ១៧៥៨ - ១៧៧៥ = ឧដុង្គ)

ព្រះបាទឧទ័យរាជា ជាព្រះរាជបុត្ររបស់ព្រះបាទធម្មរាជាអង្គអឹម ។

ក្រោយពេលដែល ព្រះអង្គនាំបក្សពួកពីដែនកូសាំងស៊ីនមកចាប់ព្រះអង្គអ៊ីង និង រាជវង្សានុវង្សធ្វើគតអស់

ហើយ ព្រះបាទឧទ័យរាជា ក៏ទ្រង់ឡើងសោយរាជ-សម្បត្តិក្នុង គ.ស. ១៧៥៨ នៅរាជធានីឧដុង្គមានជ័យ។

ដើម្បីឲ្យបានសុខជាមួយនឹងយួន ព្រះអង្គទ្រង់អនុ-ញ្ញាតអោយពួកយួនចូលមកតាំងទីលំនៅ នៅខេត្តត្រាំង និង ខេត្តត្រាវិញ ។ ប៉ុន្តែយួននៅតែមិនស្កប់ចិត្ត ពួកវាបានចូលមកនៅដល់ផ្សារដែកគូឡៅយ៉ាង និងចូវដុក-ទៀត ។

លុះមកដល់ គ.ស. ១៧៦៩ ព្រះចៅពញាតាក (សៀម) ក៏ញុះញង់បបួលព្រះអង្គនន់ (ព្រះរាជបុត្ររបស់ព្រះបាទជ័យជេដ្ឋាទី ៥ ) លើកទ័ពតាមជើងគោក ផង តាមជើងទឹកផង មកច្បាំងនឹងព្រះបាទឧទ័យរាជា ដើម្បីដណ្តើមរាជ្យ ។ កងទ័ពរបស់ព្រះអង្គទន់ដៃ, ព្រះបាទឧទ័យរាជាក៏ទ្រង់ភៀសទៅគង់នៅឯព្រៃនគរ ហើយក៏ចេះតែខំច្បាំងតយុទ្ធនឹងទ័ពសៀម និង ទ័ពព្រះអង្គនន់ជាយូរឆ្នាំ ។ ប៉ុន្តែដោយព្រះអង្គទ្រង់ឃើញថា ប្រជារា-ស្ត្រមានសេចក្តីទុក្ខវេទនាជាខ្លាំងដោយសារសង្គ្រាមនេះ ព្រះឧទ័យរាជា ក៏ទ្រង់លើករាជសម្បត្តិថ្វាយមកព្រះអង្គ-នន់ ដើម្បីកុំអោយប្រជារាស្ត្រមានសេចក្តីទុក្ខវេទនា និង សង្គ្រាមតទៅទៀត ។

# ៧០ – ព្រះបាទអង្គនន់ទី ២

(គ.ស. ១៧៧៥ – ១៧៧៩ = ឧដុង្គ)

ព្រះបាទអង្គនន់ទី ២ ជាព្រះរាជបុត្ររបស់ព្រះបាទ-ជ័យជេដ្ឋាទី ៥ ។ ព្រះអង្គទ្រង់ឡើងសោយរាជសម្បត្តិក្នុង គ.ស. ១៧៧៥ នៅរាជធានីឧដុង្គមានជ័យ ។

ក្នុងរាជ្យរបស់ព្រះអង្គ មាននាម៉ឺនខ្មែរម្នាក់ឈ្មោះស្រីស្តីទី ជាវិបុល្លរាជ ភូឈ្មួយក្រឡាហោម មានបំណងចង់ធ្វើគតព្រះអង្គ ។ ប៉ុន្តែព្រះអង្គទ្រង់ជ្រាបការណ៍នេះមុនក៏ចាប់នាម៉ឺននោះសម្លាប់ចោលទៅ ។

ឯជំទាវឡុង់ជាម្តាយលោកវិបុល្លរាជស្រី ក៏ប្រមូលកូនប្រុស ៤ នាក់គឺ ឧកញ៉ាទែន ចៅហ្វាយខេត្តកំពង់ស្វាយ ចៅហ្វាមូ ចៅហ្វាយខេត្តត្រាំង ,ឧកញ៉ាពាង ចៅហ្វាយស្រុកបារាយណ៍ និង ឧកញ៉ាសំ ចៅហ្វាយស្រុកព្រៃក្ដី ឲ្យសងសឹកនឹងព្រះអង្គនន់ទី ២ វិញ ។ គាប់ជួនជាពេលនោះ សៀមលើកទ័ពទៅឡាំងនិងលាវហើយសុំឲ្យស្ដេចខ្មែរជួយ ។ ដោយសារព្រះអង្គដឹងគុណសៀម ព្រះអង្គក៏លើកទ័ពទៅជួយ ។ ប្រជារាស្ត្រមានសេចក្តីក្តៅក្រ-ហាយ ក៏នាំគ្នាពួតដៃជាមួយនឹងពួកនាម៉ឺនបង្កជាកងទ័ពលើកទៅឡាំងនឹងព្រះអង្គនន់ទី ២ ហើយក៏ចាប់ព្រះអង្គ

យកទៅធ្វើគតក្នុងទឹកបឹងក្បៀយព្រះជន្ម ក្នុង គ.ស.-១៧៧៩ ។

## ៧១- ព្រះបាទសម្តេចព្រះអង្គអេង

(គ.ស. ១៧៧៩ - ១៧៩៦ = ខុស្ក)

ព្រះបាទសម្តេចព្រះអង្គអេង ជាព្រះរាជបុត្ររបស់ព្រះឧទ័យរាជា ( ព្រះអង្គតន់ ) ។ ក្នុង គ.ស. ១៧៧៩ ក្រោយពេលដែលគេធ្វើគតព្រះបាទអង្គនន់ទី២ រួចហើយ នាម៉ឺនសព្វមុខមន្ត្រី និង ព្រះរាជវង្សានុវង្ស ក៏ប្រជុំព្រមព្រៀងគ្នាលើករាជសម្បត្តិថ្វាយទៅ ព្រះបាទសម្តេចព្រះ-អង្គអេង ដែលទើបតែមានព្រះជន្ម ៦ ព្រះវស្សា ។

លុះមកដល់ គ.ស. ១៧៨៣ ប្រទេសកម្ពុជាមានកើតចលាចលដោយសារ លោកឧកញ៉ាអរជូន ចៅហ្វាយខេត្តត្បូងឃ្មុំ បានលើកទ័ពមកចាប់សម្តេចចៅហ្វ៊ាបែន និង ឧកញ៉ាក្រឡាហោមប៉ុក ជាព្រះបិតាធម៌ របស់ព្រះបាទសម្តេចអង្គអេង ។ សម្តេចចៅហ្វ៊ាបែន ឃើញថាតយុទ្ធមិនឈ្នះក៏អញ្ជើញព្រះបាទសម្តេចព្រះអង្គអេង ស្តេចយាងចូលទៅគង់នៅឯបាងកក ។

លុះព្រះអង្គមានព្រះជន្ម ២១ ព្រះវស្សាគឺក្នុង គ.ស.-១៧៩៤ ព្រះអង្គយាងចូលឧបសម្បទ ជាព្រះភិក្ខុនៅវត្ត

ព្រះរតនសាស្តារាម ហើយក៏យាងទៅគង់នៅវត្តសារាយ ដល់ពេលចេញព្រះវស្សាព្រះអង្គទ្រង់ដាក់ព្រះផ្នួស ។ព្រះចៅពុទ្ធយ៉តហ្វា (សៀម) បានធ្វើពិធីអភិសេកព្រះបាទសម្តេចព្រះអង្គអេង អោយឡើងសោយរាជសម្បត្តិលើប្រទេសកម្ពុជាម្តងទៀត ហើយតាំងខុកញ៉ាប៉ុកជាសម្តេចចៅហ្វាទឡហៈ ជានាក់កាន់កាប់កិច្ចការផែនដី ។ ប៉ុន្តែព្រះចៅប្រទេសសៀមសុំយកខេត្តបាត់ដំបង និង សៀមរាប អោយនាំស្ទួយទៅប្រទេសវាដោយតាំងចៅពញាអភ័យភូបេតបែន ជាអ្នកត្រួតត្រា ។

ព្រះបាទសម្តេចព្រះអង្គអេង មានព្រះរាជបុត្រ ៥-ព្រះអង្គ គឺ ១-ព្រះអង្គចន្ទ , ២-ព្រះអង្គភិម , ៣-ព្រះអង្គស្ងួន , ៤-ព្រះអង្គអឹម , និង ៥-ព្រះអង្គឌួង ។

ព្រះបាទសម្តេចអង្គអេងទ្រង់សុវណ្ណគតដោយសារសរោគនៅថ្ងៃសុក្រ ខែសីហា ឆ្នាំ ១៧៩៦ ក្នុងព្រះជន្ម ២៥ ព្រះវស្សា ។

# ៧២ - សម្ដេចចៅហ្វាប៉ុក

(គ.ស. ១៧៩៦ - ១៨០៦)

ក្រោយពេលដែលព្រះបាទអង្គអេង ទ្រង់សោយ-ទិវង្គត់ទៅ , ប្រទេសកម្ពុជាពុំមានព្រះមហាក្សត្រសោយរាជ្យ ១០ ឆ្នាំ គឺពី គ.ស. ១៧៩៦ ដល់ ១៨០៦ ព្រោះព្រះចៅប្រទេសសៀម,មិនព្រមថ្វាយរាជ្យទៅព្រះរាជបុត្ររបស់ព្រះបាទសម្ដេចអង្គអេងសោះ ដោយគេអាងថានៅតូច ៗ ពេក ហើយគេបែជាតាំងសម្ដេចចៅហ្វាប៉ុកឲ្យកាន់នាទី ជាអ្នកសម្រេចកិច្ចការផែនដីទៅវិញ ។

ក្នុងការគ្រប់គ្រងកិច្ចការរដ្ឋរបស់សម្ដេច ចៅហ្វាប៉ុកនេះ ប្រទេសកម្ពុជាមិនសូវបានសេចក្ដីសុខសប្បាយទេ ព្រោះព្រះចៅប្រទេសសៀមសុំឲ្យសម្ដេចចៅហ្វា លើកទ័ពទៅជួយច្បាំងនឹងភូមា ។ ហើយព្រះចៅប្រទេសអណ្ណាម ព្រះនាម (យ៉ា-ឡុង) បានពឹងព្រះចៅប្រទេសសៀម ឲ្យទ្រង់មានព្រះបញ្ញាមកសម្ដេចចៅហ្វាប៉ុក ឲ្យលើកទ័ពទៅជួយច្បាំងនឹងតៃសឺនដែលដណ្ដើមរាជ្យ ។ សម្ដេចចៅហ្វាប៉ុកមានជ័យជំនះក្នុងសង្គ្រាមទាំងពីរដង-នេះ ។ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជាវិញតែងមានការបះបោរ ដោយពួកចៅហ្វាយខេត្តទាំងឡាយ ចង់វាយ

ចំណែកដែនដីដែលខ្លួនត្រួតត្រានោះ ឲ្យបានដាច់មុខតែ ឯង ដោយមិនចាំបាច់យកពន្ធដារ អាករឡើងមកសម្តេច ចៅហ្វាឡើយ ។

ព្រះចៅប្រទេសសៀមឃើញហេតុមិនស្រួលដូច្នេះ ក៏ទ្រង់បញ្ជូនព្រះអង្គចន្ទឲ្យមកសោយរាជ្យវិញ ។

ចំណែកសម្តេចចៅហ្វាប៉ុក ព្រះចៅប្រទេសសៀមក៏ទទួលយកទៅឲ្យនៅឯប្រទេសសៀមរហូតដល់អាយុ ៦៥ ឆ្នាំ ក៏អនិច្ចកម្មទៅ ។

## ៧៣ - ព្រះបាទអង្គចន្ទទី ២

(គ.ស. ១៨០៦ - ១៨៣៤ = ២៨ឆ្នាំ)

ព្រះបាទអង្គចន្ទទី ២ ជាព្រះរាជបុត្រច្បង នៃព្រះ-បាទអង្គអេង ។ ព្រះអង្គបានឡើងសោយរាជសម្បត្តិក្នុង គ.ស. ១៨០៦ ក្នុងព្រះជន្ម ១៦វស្សា ដោយហេតុព្រះចៅប្រទេសសៀមរៀបចំអភិសេកឡើង ។ គ្រានោះយួនក៏បានលើកទ័ពមកវាយប្រទេសខ្មែរ បង្ខំព្រះបាទអង្គចន្ទ-ទី ២ អោយដាក់ប្រទេសចំណុះរបស់វា ។

ដោយហេតុខ្លាចក្រែងប្រជារាស្ត្ររបស់ព្រះអង្គរងទុក្ខវេទនាដោយសារសង្គ្រាម ទើបព្រះបាទអង្គចន្ទទី២ សុខ

ព្រះទ័យដាក់ប្រទេសកម្ពុជា ជាចំណុះប្រទេសអណ្ណាម ។

ក្នុងរាជ្យព្រះអង្គ មានកើតរឿងហេតុជាមួយនឹងប្រទេសសៀមជាច្រើនដងណាស់ ដោយសារព្រះចៅប្រទេសសៀមមានបញ្ជាឲ្យ ខ្មែរលើកទ័ពទៅជួយការពារប្រទេសគេ ប៉ុន្តែព្រះអង្គពុំរវាល់ធ្វើតាម ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានដាក់ទោសប្រហារជីវិត ឧកញ៉ាក្រឡាហោមមឿង និង ឧកញ៉ាចក្រីបែន ដែលសមគំនិតនឹងព្រះអង្គស្ងួន ព្រោះអ្នកទាំងពីរនេះ បានលួចកេណ្ឌទ័ពទៅជួយសៀម ។

ក្រោយមកលោកតេជោមឿង ចៅហ្វាយខេត្តកំពង់ស្វាយ បានលើកទ័ពមកច្បាំងនឹងព្រះអង្គ ប៉ុន្តែព្រះអង្គបង្ក្រាបបានវិញ ។

លុះមកដល់ គ.ស. ១៨១៤ ពួកសៀមលើកទ័ពមកវាយយកខេត្តមលូព្រៃ , ទន្លេពៅ , និង ស្ទឹងត្រែង ។

ក្នុង គ.ស. ១៨២៨ លោកចៅហ្វាយខេត្តពោធិសាត់ បាននាំបក្សពួករត់ចូលទៅនៅក្នុងប្រទេសសៀម ហើយសូមអោយព្រះចៅប្រទេសសៀម ជួយលើកទ័ពមកវាយប្រទេសកម្ពុជា ។

លុះចូលមកក្នុង គ.ស. ១៨២៩ ពួកសៀមក៏ចាត់ឲ្យពញាឱន លើកទ័ពមកវាយប្រទេសកម្ពុជាយ៉ាងសម្ងាត់

រហូតដល់ខែត្រពោធិសាត់ ។ ព្រះបាទសម្តេចអង្គចន្ទទី២ ក៏រំដោះព្រះអង្គយាងទៅគង់នៅឯព្រៃនគរ ។ ប៉ុន្តែមកដល់ គ.ស.១៨៣១ ប្រទេសអណ្ណាមក៏លើកទ័ពមកកំចាត់ពួកសៀមចេញពីប្រទេសកម្ពុជា ហើយក៏អញ្ជើញព្រះបាទសម្តេចអង្គចន្ទទី ២ អោយយាងត្រឡប់មកសោយរាជ-សម្បត្តិវិញ ។

ព្រះបាទសម្តេចអង្គចន្ទទី ២ ទ្រង់សុវណ្ណគត នៅក្នុង គ.ស. ១៨៣៤ ។

## ៣៤ – សម្តេចព្រះមហាក្សត្រិយានីអង្គមី

(គ.ស. ១៨៣៤ – ១៨៤១ = ៦ជុំក្ត)

កាលព្រះបាទអង្គចន្ទទី ២ ទ្រង់សុវណ្ណគតទៅ ព្រះ-អង្គ គ្មានព្រះរាជបុត្រាទេ មានតែព្រះរាជបុត្រី ៤ ព្រះអង្គ គឺ ÷ ១-ព្រះអង្គម្ចាស់ក្សត្រីបែន , ២-ព្រះអង្គ-ម្ចាស់ក្សត្រីមុឺ , ៣- ព្រះអង្គម្ចាស់ក្សត្រីពៅ និង ៤- ព្រះអង្គម្ចាស់ក្សត្រីស្ងួន ។

នេះសមនឹងគំនិតសៀមដែលប្រាថ្នាចំបាត់ វង្សក្សត្រខ្មែរ ទាំងយួនក៏ដូច្នេះដែរ យួនមិនព្រមតាំងព្រះអង្គ-អិម ឬ ព្រះអង្គឌួង ជាព្រះមហាក្សត្រខ្មែរទេ បែរទៅ

តាំងព្រះអង្គម្ចាស់ក្សត្រីបែន អោយសោយរាជ្យទៅវិញ។
តែព្រះអង្គម្ចាស់ក្សត្រីបែនមិនព្រម ។ យួនក៏ទៅតាំងព្រះអង្គម្ចាស់ក្សត្រីម៉ីជាស្ដេចផែនដី ។ នៅក្នុងរាជ្យព្រះរាជក្សត្រីអង្គម៉ីនេះ កិច្ចការរាជការធ្លាក់ទៅលើមេទ័ពយួនបីនាក់គឺ ទ្រឿងមិញយ៉ាង១ , ផាំវ្យាំងយ៉ាង១ ,ត្រឹងវ្យាំងណាង១ ។ យួនបញ្ចេញអំណាចយ៉ាងឃោរឃៅមកលើរាស្ត្រខ្មែរ បង្ខំឲ្យនាម៉ឺនខ្មែរស្លៀកពាក់ជាយួន អោយរាជការខ្មែររកអាហារចិញ្ចឹមទាហានយួន, ឲ្យកាប់ដើមពោធិ៍ អោយបោះបង់ព្រះពុទ្ធរូបចោលហើយឲ្យហៅទីក្រុងចតុមុខថា (( ណាំយ៉ាងវិញ )) ។ អំពើនេះរាស្ត្រខ្មែរកើតក្ដីក្ដៅក្រហាយជាខ្លាំងហើយបះបោរឡើង ដេញយួនចេញពីព្រះរាជនគរ ទើបទៅសុំព្រះអង្គឌួងពីព្រះចៅសៀម ឲ្យស្ដេចយាងមកសោយរាជ្យនៅនគរកម្ពុជាក្នុង គ.ស. ១៨៤១ ។

# ៧៥ – ព្រះបាទសម្តេចព្រះហរិរក្សរាមាធិបតី
# ( ព្រះអង្គឌួង )

(គ.ស. ១៨៤១ - ១៨៦០ =ឧដុង្គ)

ព្រះបាទសម្តេចព្រះហរិរក្សរាមាធិតី ជាព្រះរាជពៅរបស់ព្រះបាទអង្គអេង ។

សម័យដែលព្រះអង្គទ្រង់ឡើងគ្រងរាជសម្បត្តិនោះជាសម័យដែលប្រទេសកម្ពុជា ធ្លាក់ចុះក្នុងការវិបត្តិធ្ងន់ធ្ងរណាស់ទៅហើយ ដោយហេតុតែមានការច្បាំងគ្នាញឹកញាប់ពេកក្នុងពេលពីមុនៗ មក ។ យួនលើកទ័ពមកវាយប្រទេសកម្ពុជាអស់ពេល៦ឆ្នាំ ចាប់តាំងពី គ.ស. ១៨៤១ រហូតដល់ គ.ស. ១៨៤៧ ប៉ុន្តែមិនចាញ់មិនឈ្នះឡើយ ។

ព្រះអង្គទ្រង់រង់ចាំ៦ឆ្នាំទើបបានទទួលនូវរាជាភិសេកក្នុង គ.ស. ១៨៤៧ នៅរាធានីឧដុង្គមានជ័យ ។ ក្នុងពេលធ្វើពិធីរាជាភិសេកនេះ យួន និង សៀមតាំងខ្លួនជាម៉ែឪលើប្រទេសខ្មែរ ។ លុះព្រះអង្គទទួលរាជាភិសេកហើយ សៀមក៏កំហែងយកខេត្តបាត់ដំបង , ទន្លេពៅ និង មង្គលបុរី ជារបស់វា តែព្រះអង្គពុំព្រម ។

ដើម្បីនឹងចៀចវាងនូវសត្រូវទាំងសងខាង គឺសៀម និង យួន ព្រះបាទសម្តេចព្រះហរិរក្សរាមាធិបតីទ្រង់យក

ប្រទេសបារាំងធ្វើជាអាណាព្យាបាល ។ ពេលនោះយួនក៏សុខចិត្តយកព្រះអង្គម្ចាស់ក្សត្រីអង្គម៉ី ព្រមទាំងព្រះរាជវង្សានុវង្សដែលវាឃុំទុកនៅឯព្រៃនគរនោះមកថ្វាយព្រះអង្គវិញ ។

ព្រះបាទសម្តេចព្រះហរិក្សរាមាធិបតី ជាក្សត្រប្រកបដោយទសពិធរាជធម៌ ជាក្សត្រសន្តិភាព ។ ព្រះអង្គទ្រង់មានមេត្តាករុណាចំពោះប្រជារាស្ត្ររបស់ព្រះអង្គណាស់ ។

ព្រះអង្គជាពុទ្ធសាសនូបត្ថម្ភក៍ ។ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យនឹងអក្សរសាស្ត្រណាស់ ។ ព្រះអង្គជាកវីនិពន្ធដ៏ឆើត ។ ព្រះអង្គទ្រង់បានសាងផ្លូវថ្នល់មួយពីឧដុង្គទៅ កំពត ។ ព្រះអង្គទ្រង់បានចាត់កិច្ចការរដ្ឋ ឲ្យមានរបៀបរៀបរយល្អក្នុងប្រទេស ។

ព្រះបាទសម្តេចព្រះហរិក្សរាមាធិបតី ទ្រង់មានព្រះរាជបុត្រ ៣ ព្រះអង្គ គឺ ៖ ព្រះអង្គរាមាវតី (នរោត្តម)១, ព្រះស៊ីសុវត្ថិ ១ , និង ព្រះអង្គវរវត្តា (ស៊ីវត្ថា) ១ ។

ព្រះអង្គទ្រង់ព្រះសុវណ្ណគត នៅក្រុងឧដុង្គមានជ័យក្នុង គ.ស. ១៨៦០ ។

# ៧៦- ព្រះបាទសម្តេចនរោត្តម

(១៨៦០ - ១៩០៤ =ឧដុង្គ-ភ្នំពេញ)

ព្រះបាទសម្តេចនរោត្តមជាព្រះរាជបុត្រទី ១ នៃព្រះបាទអង្គឌួង ។ ក្នុងរាជ្យរបស់ព្រះអង្គ ប្រទេសកម្ពុជាស្ថិតនៅក្នុងការទំនុកបំរុងរបស់បារាំងសែស ។

លុះព្រះអង្គសោយរាជ្យបាន ១ ឆ្នាំ ព្រះវៃវត្ថាជាព្រះអនុជកើតក្តីច្រណែននឹងរាជសម្បត្តិ ក៏ទៅចាត់មនុស្សពីរនាក់ឈ្មោះ (( ស្នងសូរ ))និង ( មនោកែវ ) ឲ្យធ្វើជាមេបះ តែត្រូវទ័ពហ្លួងវាយខ្ចាត់ខ្ចាយអស់ ហើយចាប់បាន (( មនោកែវ )) សម្លាប់ចោលទៅ ៦ ((ស្នង-សូរ )) រត់រួចចូលទៅដែនកូសាំងស៊ីន ។ ចំណែកព្រះ-វៃវត្ថាក៏ភៀសព្រះអង្គបាត់ទៅដែរ ។

ព្រះបាទនរោត្តមទ្រង់បានផ្លាស់រាជធានីពីឧដុង្គ មកតាំងនៅភ្នំពេញជាប់រហូតមកដល់សព្វថ្ងៃនេះ ។

លុះដល់ គ.ស. ១៨៦៥ មានមេក្បត់ពីរនាក់ទៀត , គឺ អាចារ្យ (( ស្វា )) និង (( ពោធិកំបោរ )) នាំគ្នាបំពះបំបោរប្រជារាស្ត្រក្នុងព្រះនគរឡើង តែត្រូវទ័ពហ្លួងសម្លាប់បានទាំងអស់ ។ រួចពីនោះមកនគរកម្ពុជាក៏បានសាន្តត្រាណ។ នៅ គ.ស. ១៨៧២ ព្រះបាទនរោត្តម

បានយាងទៅ ក្រុងហុងកុងដើម្បីទតរាជការប្រទេសគេ ហើយត្រឡប់មកក្រុងម៉ានិល ( ហ្វីលីពីន ) ព្រមទាំងបាន នាំយកភ្លេងម៉ានិល ១ វង់មកផង ។ ទ្រង់បានសាងព្រះវិហារព្រះកែវមរតក នៅខាងត្បូងព្រះបរមរាជវាំងភ្នំពេញ ។

ព្រះអង្គទ្រង់សុវណ្ណគតនៅ គ.ស. ១៩០៤ ។

## ៧៧- ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ

( ១៩០៤ - ១៩២៧ = ភ្នំពេញ )

ព្រះបាទស៊ីសុវត្ថិជាព្រះអនុជព្រះបាទនរោត្តម ដែល ត្រូវជាព្រះរាជ្យបុត្រព្រះបាទអង្គឌួង ។ កាលព្រះបាទ នរោត្តមទ្រង់ព្រះសុវណ្ណគតទៅ , គណៈរដ្ឋមន្ត្រី ,សម្តេច សង្ឃទាំងពីរគណៈ និង លោករ៉េស៊ីដង់ស៊ុបេរិយ៉េរ បាន ព្រមព្រៀងគ្នា លើករាជ្យថ្វាយមកព្រះអង្គ ។

ព្រះអង្គទទួលរាជាភិសេកហើយ គេថ្វាយព្រះនាមថា (( ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ )) ។ បន្ទាប់មកទ្រង់បាន យាងទៅប្រទេសបារាំង ដើម្បីទតរបៀបរាជការប្រទេស គេ ។ កាលពី គ.ស. ១៩០៤ សៀមបានប្រគល់ខែត្រ-

ស្ទឹងត្រែង , ទន្លេពៅ និង ព្រៃឆ្លូ មកឲ្យខ្មែរវិញ ។ លុះដល់មកថ្ងៃទី ២៣ មីនា ឆ្នាំ ១៩០៧ សៀមបានធ្វើសន្ធិសញ្ញានឹងបារាំង ប្រគល់ខេត្តបាត់ដំបង , សិរីសោភ័ណ, សៀមរាបមកអោយខ្មែរទៀត ។ ព្រះបាទស៊ីសុវត្ថិ បានអនុញ្ញាតឲ្យខ្មែរស្ម័គ្រចិត្តទៅជួយច្បាំងបារាំងកាលបារាំងធ្វើសង្គ្រាម និង អាល្លឺមង់ ( ១៩១៤ - ១៩១៨ )។ ឈ្មោះខ្មែរដែលអនិច្ចកម្មក្នុងសង្គ្រាមនោះ សឹងមានចារឹកទុកក្នុងចេតិយ៍អនុស្សាវរីយ៍របពីរ នៅភ្នំពេញក្នុងឆ្នាំ ១៩២៥ ។

ក្នុងរាជ្យរបស់ព្រះអង្គ ប្រទេសកម្ពុជាបានសុខសប្បាយណាស់ ។ ទ្រង់បានចាត់ឲ្យសាងវិទ្យាល័យហៅថា (( វិទ្យាល័យស៊ីសុវត្ថិ )) សាងរាជបណ្ណាល័យ , សាលាបាលីជាន់ខ្ពស់ ,សាលារចនា ,សាលាបង្រៀនធ្វើរាជការ និង បង្កើតផ្លូវថ្នល់ទៅមកគ្រប់ខេត្តទាំងអស់ ។

# ៣៨- ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ-មុនីវង្ស

( ១៩២៧ - ១៩៤១ = ភ្នំពេញ )

ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ-មុនីវង្ស ជាព្រះរាជបុត្រច្បងនៃព្រះបាទស៊ីសុវត្ថិ ។ ទ្រង់ឡើងសោយរាជ្យក្នុង គ.ស. ១៩២៧ តពីព្រះវររាជបិតា ។

ក្នុងរាជ្យព្រះអង្គប្រទេសកម្ពុជាយើង ស្ថិតនៅក្រោមអាណាព្យាបាលរបស់បារាំងសែស ។ ពិតមែនតែស្រុកបានសុខសប្បាយ តែអាណានិគមនិយមបារាំងសែស បានបិទសិទ្ធិសេរីភាព និង ជិះជាន់ប្រជាជនខ្មែរជាខ្លាំងណាស់. សម័យនោះរាស្ត្រខ្មែរស្គាល់តែសេចក្ដី វេទនា គ្រប់បែប-គ្រប់យ៉ាង ។

ក្រុមហ៊ុនបារាំងបានដាំកៅស៊ូជាលើកដំបូង នៅប្រ-ទេសកម្ពុជា ( មេមត់ ) លើផ្ទៃដី ៦.០០០ ហិកតារ មានដើមកៅស៊ូ ៨៥០.០០០ ដើម ដែលជាចំការធំជាងគេក្នុងពិភពលោក ។ នៅចុងខែមិនា គ.ស. ១៩៣២ រាជរដ្ឋាភិបាលខ្មែរបានធ្វើពិធីសម្ពោធផ្លូវអយស្ម័យយានពីភ្នំពេញ ទៅកាន់ព្រំដែនសៀម កាត់តាមខេត្តបាត់ដំបងក្រោមព្រះរាជាធិបតីភាពនៃព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ-

មុនីវង្ស និង ក្រោមកិច្ចត្រួតត្រានៃអគ្គទេសាភិបាលពី

យ៉ែរបាំស្គីយេរ ។ នៅទន្លេបាសាក់ ស្ពានមួយធំជង្រ្គឹង

ត្រូវបានស្ថាបនាឡើងដែរ ហើយគេដាក់ឈ្មោះ ថា

(( ស្ពានព្រះមុនីវង្ស )) ។

ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស ទ្រង់សុវណ្ណគត នៅថ្ងៃទី ២៣ មេសា គ.ស. ១៩៤១ ។

## ៧៩- ព្រះបាទសម្តេចព្រះនរោត្តម-សីហនុវរ្ម័ន

( គ.ស. ១៩៤១ - ១៩៥៥ = ភ្នំពេញ )

ព្រះបាទសម្តេចព្រះនរោត្តម-សីហនុវរ្ម័ន ទ្រង់ប្រសូត្រនៅថ្ងៃទី ៣១ តុលា ឆ្នាំ ១៩២២នៅក្រុងភ្នំពេញ។ ព្រះអង្គជាព្រះរាជបុត្រ នៃព្រះករុណាព្រះបាទសម្តេច-នរោត្តម-សុរាម្រិត និង ព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ-នារីរ័ត្ន ។ ព្រះអង្គត្រូវជាព្រះរាជនត្តោទួត នៃព្រះបាទសម្តេចនរោត្តម ខាងព្រះវង្សព្រះបិតា, ជាព្រះរាជនត្តោ នៃព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស និងត្រូវជាព្រះរាជនត្តោទួត នៃព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ខាងព្រះវង្ស-

ព្រះវររាជមាតា ។

ដូច្នេះព្រះរាជសន្តតិវង្សទាំងពីរខាង នៃព្រះបាទសម្តេចព្រះនរោត្តម-សីហនុវរ្ម័ន ចេញមកពីព្រះបាទអង្គ-ឌួង ដែលជាព្រះរាជសន្តតិវង្សដ៏ខ្ពង់ខ្ពស់ជាដំណរហូតតាំងពីព្រះមហាក្សត្រទាំងឡាយនៃសម័យអង្គរ ។

ក្រោយដែលព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស ជាព្រះរាជអយ្យកោទ្រង់ចូលព្រះទិវង្គត់ទៅ ក្រុមប្រឹក្សាព្រះរាជសម្បត្តិបានព្រមព្រៀងគ្នាទៅយាងព្រះអង្គម្ចាស់នរោ-ត្តម-សីហនុ ដែលព្រះអង្គកំពុងតែបំពេញវិជ្ជានៅវិទ្យា-ល័យ ( សាស្ស៊ីលូឡូបាត៍ ) ឯ ក្រុងព្រៃនគរ ដើម្បីមកសោយរាជសម្បត្តិ ។ ព្រះរាជាភិសេកបានប្រព្រឹត្តទៅនៅក្នុងឆ្នាំ ១៩៤១ ។ ប៉ុន្តែជាអកុសលផងដែល គឺប្រទេសយើង នៅជាប់ជាប្រទេសអាណាព្យាបាលរបស់បារាំង ។

នៅរាត្រីថ្ងៃទី ៩ មីនា ឆ្នាំ ១៩៤៥ កងទ័ពជប៉ុនបានឡោមព័ទ្ធបារាំង ហើយថ្វាយរាជ្យមកព្រះមហាក្សត្រខ្មែរ ។ ប៉ុន្តែមិនបានប៉ុន្មាន កងទ័ពបារាំងចូលមកញាំញីឯករាជ្យនេះតទៅទៀត ។

នៅខែធ្នូ ឆ្នាំ ១៩៤៧ សៀមបានប្រគល់ដីខេត្ត-បាត់ដំបង ដែលបានទៅសៀមតាមសន្ធិសញ្ញានាក្រុងតូក្យូ

ពីឆ្នាំ ១៩៤០ មកប្រទេសកម្ពុជាវិញ ។

ដល់មក គ.ស. ១៩៤៩ បារាំងបានព្រមព្រៀងចុះសន្ធិសញ្ញាមួយនៅក្រុងប៉ារី (ប្រទេសបារាំង) ព្រមប្រគល់ឯករាជ្យមកខ្មែរទៀត តែត្រូវនៅក្នុង (សហភាពបារាំង)

លុះដល់ គ.ស. ១៩៥៣ ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ទ្រង់យាងចាកចេញទៅកាន់ មហាប្រទេសនានាដើម្បីនឹងធ្វើព្រះរាជសកម្ម ប្រយុទ្ធទាមទារឯករាជ្យបរិបូណ៌ពីបារាំង ។ កាលទ្រង់យាងត្រឡប់មកដល់ប្រទេសកម្ពុជាវិញ ព្រះអង្គបានបង្កើតផែនការមួយ ដោយដាក់ព្រះនាមព្រះអង្គថា (( ផែនការព្រះសីហនុ )) អាស្រ័យផែនការនេះ បណ្តាជនខ្មែរទាំងប្រុសស្រីគ្រប់ឋានៈក្រោកឡើងហ្វឹកហ្វឺនខ្លួនជា កងយោធាដែលហៅថា ((កងជីវពល និង នារីក្លាហាន)) ស្រុះស្រួលគ្នាដង្ហែតាមព្រះមហាវីរក្សត្ររបស់ខ្លួន លុះត្រាតែបារាំងទ្រាំមិនបានក៏ព្រមប្រគល់សមត្ថកិច្ចធំ ៗ ដែលជាកេតនណ្ឌឯករាជ្យ មករាជការខ្មែរបានពេញបរិបូណ៌ ជារដ្ឋឯករាជ្យពេញដោយអធិបតេយ្យ ។ អាស្រ័យហេតុនេះ ទើបរដ្ឋពេញទាំងប្រទេសថ្វាយ ព្រះបរមនាម ព្រះអង្គ ថា (( ព្រះបិតាឯករាជ្យ ))

ព្រះនរោត្តម-សីហនុវរ្ម័ន ព្រះអង្គជាស្តេចសឹក ដ៏

គៀវក្លាដោយទ្រង់យ៉ាងទៅ ប្រតិបត្តិការបង្ក្រាបសត្រូវ ដោយផ្ទាល់ព្រះអង្គនៅក្នុងខេត្តបាត់ដំបង ក្នុងពេលមានអសន្តិសុខដោយសារពួកឥស្សរៈ និង យៀកមិញ ។

ព្រះប្រិយមហាក្សត្រអង្គនេះ ទ្រង់ជាសាសនូបត្ថម្ភក៍ ហើយទ្រង់បានចូលព្រះផ្នួសជាព្រះភិក្ខុ នៅវត្តព្រះកែវមរកតអស់រយៈ ១ ព្រះវស្សា ( គ.ស.១៩៤៧ ) ។ ព្រះអង្គប្រកបដោយទសពិធរាជធម៌ និង មានព្រះទ័យសន្តោសមេត្តាជានិច្ច ទ្រង់បានបង្កើតសង្គហជាតិ សំរាប់ជួយសង្គ្រោះដល់ជនអ្នកក្រីក្រ និងរងគ្រោះថ្នាក់ផ្សេងៗ។

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ទ្រង់បានប្រោសព្រះរាជទានរដ្ឋធម្មនុញ្ញ លទ្ធិប្រជាធិបតេយ្យ មកប្រជានុរាស្ត្រជាទីស្នេហារបស់ព្រះអង្គ ពីថ្ងៃ៦ ឧសភា១៩៤៧ មិនតែប៉ុណ្ណោះព្រះអង្គសព្វព្រះរាជហឫទ័យជាបំផុត ក្នុងវិស័យសិក្សាធិការដោយទ្រង់បានចំណាយព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ សង់គ្រឹះស្ថានសិក្សាមួយនៅខេត្តកំពង់ចាម ដែលមានឈ្មោះថា (( វិទ្យាល័យព្រះសីហនុ )) និង បានចំណាយព្រះរាជទ្រព្យផ្ទាល់ព្រះអង្គ ជួយសាងអនុវិទ្យាល័យព្រះសូរ្យវង្សទី ២ នៅខេត្តសៀមរាប ។ព្រះរាជទ្រព្យនេះសង់បានសាលាមួយខ្នងធំ ចំនួន ១ លាន ៥សែនរៀលទៀត ជួយកសាង (( ពុទ្ធិកមហាវិទ្យាល័យ

ព្រះសីហនុរាជ ))និងចំណាយព្រះរាជទ្រព្យផ្ទាល់ព្រះអង្គជួយឧបត្ថម្ភការកសាងគ្រប់យ៉ាង ដែលប្រទេសជាតិត្រូវការហើយនិងទ្រង់ជួយឧបត្ថម្ភដល់និស្សិតខ្មែរឲ្យបន្តវិជ្ជាងបរទេសផង ។

ដោយសារព្រះប្រាជ្ញាវាងវៃនៃព្រះមហាក្សត្រអង្គនេះទើបប្រទេសខ្មែរ បានចូលជាសមាជិកនៃអង្គការសហប្រជាជាតិកាល ពី គ.ស. ១៩៥៥ និង ណែនាំខ្មែរឲ្យកាន់នយោបាយបរទេសជារដ្ឋអព្យាក្រិត្យឥតមានលំអៀង ។

ព្រះអង្គទ្រង់ដាក់រាជសម្បត្តិនៅថ្ងៃទី ២ ខែ មិនា គ.ស. ១៩៥៥ ដើម្បីរៀបចំធ្វើចលនាបង្រួបបង្រួមជាតិឈ្មោះ (សង្គមរាស្ត្រនិយម ) ដែលជាអង្គការមួយណែនាំរាស្ត្រតូចតាចឲ្យស្គាល់លទ្ធិប្រជាធិបតេយ្យដ៏បរិសុទ្ធ ។

ព្រះបាទសម្តេចព្រះនរោត្តម-សីហនុវរ្ម័ន ទ្រង់សោយរាជ្យបាន ១៣ ឆ្នាំ ៤ ខែ និង ៩ ថ្ងៃ ។

# ៨០- ព្រះបាទសម្ដេចព្រះនរោត្តម-សុរាម្រិត

(គ.ស. ១៩៥៥ - ១៩៦០ -ភ្នំពេញ)

ព្រះបាទសម្ដេចព្រះនរោត្ដម-សុរាម្រិត ទ្រង់ប្រសូត្រ នៅក្រុងភ្នំពេញ កាលពីថ្ងៃទី ៦ មីនា ១៨៩៦ ពីព្រះអង្គម្ចាស់ និង ព្រះអង្គម្ចាស់ក្សត្រីនរោត្ដម-សុធារស ។ ព្រះអង្គជាព្រះរាជនត្តានៃ ព្រះបាទសម្ដេចព្រះនរោត្ដម ហើយទ្រង់ជាព្រះពីតុបតីនៃព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ-មុនីវង្ស បន្ទាប់ពីពេលដែលទ្រង់បានរៀបអាពាហ៍ពិពាហ៍ កាលពីឆ្នាំ ១៩២០ ជាមួយនឹងព្រះអង្គម្ចាស់ក្សត្រីកុសុម-នារីរត័ន៍ ដែលជាព្រះមហាក្សត្រិយានីបច្ចុប្បន្ននៃ ប្រទេសកម្ពុជា ។

ដោយហេតុមកពីការដាក់រាជ្យ នៃព្រះបាទសម្ដេច នរោត្តមសីហនុវរ្ម័ន ដែលជាព្រះរាជបុត្រដ៏ឆ្នើមនៃព្រះ-អង្គ ទើបព្រះបាទសម្ដេចព្រះនរោត្ដម-សុរាម្រិត ត្រូវបាន ក្រុមប្រឹក្សាព្រះរាជសម្បត្តិ ជ្រើសតាំងឲ្យទ្រង់សោយរាជ្យ បន្តពីព្រះរាជបុត្រព្រះអង្គ កាលពីថ្ងៃ៣ មីនា ១៩៥៥។

ក្រោយពេលដែលព្រះអង្គទ្រង់បានបំពេញវិជ្ជា នៅ អនុវិទ្យាល័យព្រះស៊ីសុវត្ថិក្រុងភ្នំពេញ និង នៅវិទ្យាល័យ

សាស្ត្រលូឡូបាត់ នា ក្រុងព្រៃនគរ ព្រះករុណាជាម្ចាស់ជីវិតលើត្បូង កាលដែលទ្រង់នៅជាព្រះអង្គម្ចាស់នៅឡើយនោះ ទ្រង់បានចូលកាន់ការរាជការ កាលពីឆ្នាំ ១៩១៨ បន្ទាប់មកទ្រង់ត្រូវបានតាំងជារាជអង្គរ័ក្ស ជាលេខាធិការផ្ទាល់នៃព្រះករុណាព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ហើយនៅថ្ងៃទី ១៥ ធ្នូ ១៩២៧ ជាប្រធាននៃក្រុមឥស្សរិយយសនៅក្នុងព្រះបរមរាជវាំង ។ ក្នុងពេលនោះទ្រង់ចាត់ចែងរៀបចំក្រុមមហាតលិក គឺនៅថ្ងៃទី ១ មីនា ១៩២៨ ។

នៅឆ្នាំ ១៩២៩ ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស ទ្រង់សព្វព្រះរាជហឫទ័យ តែងតាំងទ្រង់ជាសេនាបតីក្រឡាហោម ។ ក្នុងមុខក្រសួងសេនាបតី ព្រះអង្គទ្រង់មានឱកាសសំដែងឲ្យឃើញនូវគុណសម្បត្តិដ៏ខ្ពង់ខ្ពស់ខាងព្រះរាជបញ្ញា និង ខាងវិជ្ជាជីវៈនៃព្រះអង្គ ។

កាលពីឆ្នាំ ១៩៣២ ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ-មុនីវង្ស ទ្រង់សព្វព្រះរាជហឫទ័យ លើកព្រះរាជឋានន្តរទ្រង់ឲ្យឡើងជាក្រុមឃុនវិសុទ្ធិខត្តិយវង្ស នរោត្តមសុរាម្រិត ។

ដោយហេតុមកពីព្រះរាជគុណសម្បត្តិដ៏ឧត្តម មកពីទ្រង់មានសេចក្តីឈ្វេងយល់ដ៏ទូលាយ ហើយនិងមកពី

ទ្រង់មានចំណោះជ្រៅជ្រះនៅក្នុងប្រទេស ទើបព្រះអង្គបានចូលរួមក្នុងក្រុមប្រឹក្សារដ្ឋាភិបាល ជាច្រើនលើកច្រើនគ្រា ។

កាលពីឆ្នាំ ១៩៣៩ ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ-មុនីវង្ស ទ្រង់ប្រគល់ភារៈឲ្យព្រះអង្គ ទ្រង់កាន់កាប់បេ-សកកម្មមួយដ៏ល្អិតល្អន់អមទៅក្រសួងអាណានិគម ។ ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ទ្រង់បានបំពេញបេសកកម្មនោះ ដោយជោគជ័យយ៉ាងកម្រ ។ ដើម្បីជាព្រះរាជរង្វាន់ចំពោះកិច្ចការដែលទ្រង់បានបំពេញនោះ ព្រះអង្គទ្រង់បានឡើងព្រះរាជឋានន្តរស័ក្តិជាធិបឌិនឡេហ្ស៊ីយ៉ុង-ដោណ័រ ហើយបន្ទាប់មកទ្រង់បានឡើងជាវរៈសេនាឡេហ្ស៊ីដោណ័រទៀត ។

កាលពីរាជ្យព្រះបាទសម្ដេចនរោត្តម-សីហនុ ជាព្រះរាបុត្រដ៏ថ្លៃថ្លានៃព្រះអង្គ គឺកាលពីខែមេសា ១៩៤១ ព្រះអង្គទ្រង់បានឡើងព្រះរាជឋានន្តរស័ក្តិ ជាសម្ដេចព្រះបរមរាជបិតាវិសុទ្ធិខត្តិយវង្ស ជាមហារាជូបត្ថម្ភ ហើយព្រះអង្គតែងតែលះបង់ចោលមុខការងារក្រសួងរដ្ឋមន្ត្រី-នៃព្រះអង្គដើម្បីទ្រង់នឹងបំពេញព្រះរាជកិច្ចថ្មីនៃព្រះអង្គជាឧត្តមក្រុមប្រឹក្សារាជសម្បត្តិអោយបានសព្វគ្រប់ ។

មុនដែលព្រះអង្គ ទ្រង់បានសោយរាជសម្បត្តិ ព្រះ

ករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានកាន់ដំណែងជាប្រធាននៃក្រុមរាជានុសិទ្ធិជាច្រើនលើក ដោយទ្រង់បានកាន់កាប់ការទទួលខុសត្រូវកិច្ចការរដ្ឋ ក្នុងរយៈកាលនៃព្រះរាជបេសកកម្មស្វែងរកឯករាជ្យជាតិ នៃព្រះករុណាសម្ដេចនរោត្តម-សីហនុ ក្នុងឆ្នាំ ១៩៥២ និង ១៩៥៣។

ព្រះរាជាទ្រង់បានទទួលគ្រឿងឥស្សរិយយស មហាសិរីវឌ្ឍនអាណាចក្រកម្ពុជា ។

--- ចប់ ---

ស្តេចសោយរាជ្យលើកទី ១

នៃ ប្រទេសកម្ពុជាគឺ ៖

ព្រះបាទ ហ៊ុន ទៀន

និងស្តេចសោយរាជ្យមុនក្រោយ

បង្អស់គឺ ព្រះបាទសម្តេច-

នរោត្តម សីហនុ ។

០០៦៨ - ១៩៧០